ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ និងជំនួយស្មារតី

## សម្រាប់

## ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

## ឆ្នាំ ២០១២

# មាតិកា

ទំព័រ


**គោលបំណង** ........ ០១

**I. ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត** ........ ០២

១- ការិយាល័យចុះឈ្មោះបោះឆ្នោត និងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ........ ០២

២- ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត ........ ០៣

៣- បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត ........ ០៣

៤- សន្តិសុខ ........ ០៤

**II. ការធ្វើប្រតិភូកម្មអំណាចដល់ កបឃ/ស** ........ ០៥

១- តួនាទី និងភារកិច្ចរបស់ កបឃ/ស ........ ០៥

ក- ការធានាការអនុវត្តសិទ្ធិអំណាចដែល គ.ជ.ប បានធ្វើប្រតិភូកម្មឱ្យ ........ ០៥

ខ- ការចាត់តាំងសមាជិក កបឃ/ស ឱ្យប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ ........ ០៦

គ- ការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងចាត់ចែងសន្តិសុខ ........ ០៧

២- ភារកិច្ចរបស់មន្ត្រីចុះឈ្មោះបោះឆ្នោត ........ ០៨

ក- សេចក្តីណែនាំទូទៅសម្រាប់ស្មៀនឃុំ សង្កាត់ ........ ០៨

ខ- ការទទួលខុសត្រូវ និងភារកិច្ចរបស់ស្មៀនឃុំ សង្កាត់ ........ ០៨

៣- ការប្រើប្រាស់បញ្ជីបោះឆ្នោតចុងក្រោយឆ្នាំ២០១១ ........ ១១

**គំនូសបំព្រួញសកម្មភាពពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត** ........ ១២

**III. ជំហានសង្ខេបនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត** ........ ១៣

**IV. សិទ្ធិចុះឈ្មោះបោះឆ្នោត** ........ ១៤

១- លក្ខខណ្ឌដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត ........ ១៤

២- ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត ........ ១៦

៣- លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ........ ១៨

ក- អ្នកមានសិទ្ធិចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ........ ១៩

ខ- ការស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ........ ១៩

គ- ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ........ ១៩

ឃ- ការរក្សាសៀវភៅបញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ........ ២០

ង- ការធ្វើរបាយការណ៍អំពីការចេញលិខិតបញ្ជាក់អត្តសញ្ញាណនៅពេលបញ្ចប់ការចុះឈ្មោះ ........ ២០

ច- ការផ្ញើរបាយការណ៍ស្តីពីលទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត នៅមុនថ្ងៃបោះឆ្នោត.....២១
ឆ- សុពលភាពប្រើប្រាស់ និងទណ្ឌកម្ម.....២២
៤- នីតិវិធីចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតចុងក្រោយ.....២២
ក- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតថ្មី.....២២
ខ- ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ តែបានស្លាប់ បាត់បង់សិទ្ធិបោះឆ្នោត ផ្លាស់ទីលំនៅ....២៣
គ- ករណីអ្នកសុំប្តូរការិយាល័យបោះឆ្នោតពីឆ្ងាយមកជិតផ្ទះក្នុងឃុំ សង្កាត់.....២៤
ឃ- ករណីអ្នកសុំចុះឈ្មោះដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់ផ្សេង.....២៤
ង- ករណីអ្នកបោះឆ្នោតមានឈ្មោះស្ទួនក្នុងការិយាល័យបោះឆ្នោតតែមួយ ឬផ្សេងក្នុងឃុំ សង្កាត់តែមួយ.....២៤
ច- ករណីអ្នកពិនិត្យបញ្ជីឈ្មោះ សុំកែតម្រូវឈ្មោះ ឬទិន្នន័យដែលសរសេរមិនត្រឹមត្រូវ.....២៥
៥- ការបដិសេធការសុំចុះឈ្មោះ.....២៥
ក- មូលហេតុនៃការបដិសេធ.....២៥
ខ- នីតិវិធីនៃការបដិសេធ.....២៥
៦- ការប្តឹងតវ៉ា និងការដោះស្រាយបណ្តឹង.....២៦
ក- ការដាក់ពាក្យប្តឹងតវ៉ានៅ កបឃ/ស និងការប្រជុំសម្រេចជាសាធារណៈ.....២៦
ខ- ការដាក់ពាក្យប្តឹងតវ៉ានៅ គ.ជ.ប និងការបើកសវនាការជាសាធារណៈ.....២៧
គ- ការដាក់ពាក្យប្តឹងតវ៉ានៅក្រុមប្រឹក្សាធម្មនុញ្ញ និងការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ.....២៨
**គំនូសបំព្រួញអំពីពេលវេលានៃការប្តឹងតវ៉ា និងការដោះស្រាយបណ្តឹង**.....២៩
**V. បញ្ជីបោះឆ្នោតដំបូង**.....៣០
១- ការពិនិត្យផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពរួច.....៣០
ក- ការផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពរួច.....៣០
ខ- ការផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតបន្ថែម.....៣០
គ- ការផ្ទៀងផ្ទាត់លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះតាមការិយាល័យចាស់.....៣១
ឃ- ការផ្ទៀងផ្ទាត់លទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៃការិយាល័យបង្កើតថ្មី.....៣១
២- ការរៀបចំបញ្ជីបោះឆ្នោតដំបូង.....៣១
ក- ការផ្តុំបញ្ចូលគ្នារវាងបញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពរួចជាមួយបញ្ជីបោះឆ្នោតបន្ថែម.....៣១
ខ- ការរៀបចំបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបង្កើតថ្មី.....៣១
៣- របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត.....៣១
ក- ការបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត.....៣១
ខ- ការប្រើប្រាស់ ទ.១០១១.....៣២
៤- ការថតចម្លងបញ្ជីបោះឆ្នោតចុងក្រោយដែលធ្វើបច្ចុប្បន្នភាពរួច បញ្ជីបោះឆ្នោតបន្ថែម និងបញ្ជីបោះឆ្នោតនៃការិយាល័យបង្កើតថ្មី.....៣២

ក- ករណីស្មៀនឃុំ សង្កាត់មានលទ្ធភាពរកទីកន្លែងថតចម្លងបាន ............ ៣២
ខ- ករណីស្មៀនឃុំ សង្កាត់ពុំមានលទ្ធភាពរកទីកន្លែងថតចម្លងបាន ............ ៣២
៥- ការវេចខ្ចប់កញ្ចប់ " ក " ............ ៣៣
៦- របាយការណ៍សរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ............ ៣៤
ក- ការធ្វើរបាយការណ៍សរុបលទ្ធផល (ទ.១០១២) ............ ៣៤
ខ- ការប្រើប្រាស់របាយការណ៍សរុបលទ្ធផលក្នុងឃុំ សង្កាត់ ............ ៣៤
៧- របាយការណ៍តុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃ ............ ៣៤
៨- ការវេចខ្ចប់កញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃ (ទ.១០២២) ដែលបានប្រើហើយ ............ ៣៤
៩- ការវេចខ្ចប់កញ្ចប់ " ខ " សម្រាប់បញ្ជូនទៅ លធ / ខប ............ ៣៥
ក- ការវេចខ្ចប់កញ្ចប់ " ខ " ទី១ ............ ៣៥
ខ- ការវេចខ្ចប់កញ្ចប់ " ខ " ទី២ និងកញ្ចប់ " ខ " បន្តបន្ទាប់ ............ ៣៥
គ- ការបញ្ជូនកញ្ចប់ " ខ " មក គ.ជ.ប តាមរយៈ លធ / ខប ............ ៣៧
១០- ការត្រួតពិនិត្យកញ្ចប់ " ខ " និងការវេចខ្ចប់កញ្ចប់ " គ "នៅ លធ / ខប ............ ៣៨
ក- ការត្រួតពិនិត្យកញ្ចប់ " ខ " ............ ៣៨
ខ- ការវេចខ្ចប់កញ្ចប់ " គ " ............ ៣៨
១១- ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងសម្រាប់គោលដៅនៃការកែតម្រូវ ប្តឹងតវ៉ា ឬ / និងប្តឹងជំទាស់ ............ ៣៩
ក- ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ............ ៣៩
ខ- កាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ............ ៤០
គ- ការប្រើប្រាស់បញ្ជីបោះឆ្នោតដំបូង ............ ៤១
១២- ការសុំកែតម្រូវដោយផ្ទាល់មាត់ និងការដោះស្រាយលើបញ្ជីបោះឆ្នោតដំបូង ............ ៤១
ក- ករណីនៃការសុំកែតម្រូវដោយផ្ទាល់មាត់ ............ ៤១
ខ- រយៈពេលសុំកែតម្រូវដោយផ្ទាល់មាត់ ............ ៤១
គ- អ្នកបោះឆ្នោតមកមើលឈ្មោះ ............ ៤១
១៣- ការប្តឹង ការទទួលបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ក្នុងគោលដៅកែតម្រូវបញ្ជីបោះឆ្នោតដំបូង ............ ៤២
ក- ការប្តឹង ការទទួលបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នៅ កបឃ / ស ............ ៤២
ខ- ការប្តឹង ការទទួលបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នៅ គ.ជ.ប ............ ៤៣
គ- ការប្តឹង ការទទួលបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នៅក្រុមប្រឹក្សាធម្មនុញ្ញ និងការសម្រេច របស់ក្រុមប្រឹក្សាធម្មនុញ្ញ ............ ៤៤
ឃ- ចន្លោះពេលចាប់ពីការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង រហូតដល់ចប់ការប្តឹងតវ៉ា ឬ / និងប្តឹងជំទាស់ ស្មៀនឃុំ សង្កាត់ត្រូវធ្វើសុក្រឹតភាពបញ្ជី ............ ៤៥
ង- ពេលបញ្ចប់ដំណើរការប្តឹង និងដោះស្រាយបណ្តឹងរួចគ្រប់ថ្នាក់ ............ ៤៥

គំនូសបំព្រួញអំពីពេលវេលានៃការប្តឹងតវ៉ា និងប្តឹងជំទាស់ និងការដោះស្រាយបណ្តឹង
ក្នុងដំណាក់កាលនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង........................................................................ ៨៦

ប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១២................................................. ៨៨

តារាងសង្ខេបទម្រង់បែបបទដែលត្រូវប្រើប្រាស់តាមលំដាប់ថ្នាក់........................................................... ៨៩

# អក្សរកាត់

- គ.ជ.ប : គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លធ/ខប : លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត
- កឃ/ស : ក្រុមប្រឹក្សាឃុំ សង្កាត់
- ច.ប.ត.រ : ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ប.ន.ត.រ : បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ទ. : ទម្រង់បែបបទលេខ

# គោលបំណង

យោងជំពូកទី៦ មាត្រា៤៩ថ្មី(បី) នៃ ច.ប.ត.រ ដែលចែងថានៅឆ្នាំដែលមានរៀបចំការបោះឆ្នោតជាសកល គ.ជ.ប អាចបន្ថែមរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតយ៉ាងយូរ ៣០ថ្ងៃ គ.ជ.ប បានសម្រេចកំណត់រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតឆ្នាំ២០១២នេះ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី៣១ ខែធ្នូ ។ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២ នៅតាមឃុំ សង្កាត់ ត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ។ ប្រជាពលរដ្ឋខ្មែរត្រូវទៅការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំ សង្កាត់ ឬនៅទីតាំងណាមួយក្នុងឃុំ សង្កាត់ ដើម្បីពិនិត្យបញ្ជីឈ្មោះ ឬសុំចុះឈ្មោះបោះឆ្នោត ។ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គឺជាការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតដោយ ៖

- ការចុះឈ្មោះថ្មីចំពោះអ្នកមានសិទ្ធិបោះឆ្នោតដែលទើបគ្រប់អាយុបោះឆ្នោត អ្នកដែលពុំធ្លាប់បានចុះឈ្មោះបោះឆ្នោត និងអ្នកទើបផ្លាស់ទីលំនៅចូលមកក្នុងឃុំ សង្កាត់
- ការកែតម្រូវឈ្មោះ និងទិន្នន័យផ្សេងទៀតតាមសំណើសុំរបស់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនូវ អ្នកបោះឆ្នោតណាដែលបានស្លាប់ បាត់បង់សិទ្ធិបោះឆ្នោត ផ្លាស់ប្តូរទីលំនៅចេញពីឃុំ សង្កាត់ គ្មានទីលំនៅក្នុងឃុំ សង្កាត់ មានឈ្មោះស្ទួនលើសពីមួយក្នុងបញ្ជីបោះឆ្នោត ។

ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១២ គឺជាឱកាសដ៏សមស្របដើម្បីសម្អាតបញ្ជីបោះឆ្នោត កែតម្រូវឈ្មោះនិងទិន្នន័យអ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោតថ្មី ដើម្បីបង្កើតបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំឱ្យកាន់តែមានបច្ចុប្បន្នភាព និងសុក្រឹតភាព សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនេះ ។

សៀវភៅណែនាំ និងជំនួយស្មារតីនេះ គឺជាសេចក្តីពន្យល់អំពីបច្ចេកទេស បទប្បញ្ញត្តិ និងគោលការណ៍លើចំណុចសំខាន់ៗនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១២ សម្រាប់មន្ត្រីបោះឆ្នោត ពិសេសមន្ត្រីចុះឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ទាំងអស់ ក្នុងការរៀនសូត្រស្វែងយល់ និងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនតាមនីតិវិធីឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។ សៀវភៅណែនាំ និងជំនួយស្មារតីនេះ ក៏ជាជំនួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីសិក្សាស្វែងយល់ និងរួមសហការអនុវត្ត តាមតួនាទីរបស់ខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដើម្បីឱ្យប្រព្រឹត្តទៅស្របតាមច្បាប់ និងប្រកបដោយភាពសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព ។

# សៀវភៅណែនាំ និងជំនួយស្មារតី
# សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
# ឆ្នាំ២០១២

## I. ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

### ១. ការិយាល័យចុះឈ្មោះបោះឆ្នោត និងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

#### ក- ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

ការិយាល័យចុះឈ្មោះបោះឆ្នោតចម្បង និងការិយាល័យចុះឈ្មោះបោះឆ្នោតតាមភូមិនានា ត្រូវបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដោយផ្អែកលើបញ្ជីបោះឆ្នោតចុងក្រោយ ឆ្នាំ២០១១ ។

- ការិយាល័យចុះឈ្មោះបោះឆ្នោតចម្បង ជាការិយាល័យដែលមានទីតាំងនៅសាលាឃុំ សង្កាត់ ឬទីកន្លែងណាមួយសមស្រប ។ ការិយាល័យនេះត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅពេលចាប់ផ្តើម និងពេលបញ្ចប់ ដោយប្រើរយៈពេលប្រមាណមួយភាគពីរ(១/២)នៃរយៈពេលសរុប(ក្នុង១/២នេះ ត្រូវត្រៀម៦ថ្ងៃ សម្រាប់រយៈពេលបញ្ចប់ដែលនឹងធ្វើនៅសាលាឃុំ សង្កាត់ជាចុងក្រោយបង្អស់) ។
- ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅតាមភូមិនានា ជាការិយាល័យចុះឈ្មោះបោះឆ្នោតចល័តពីសាលាឃុំ សង្កាត់ដែលមានចម្ងាយលើសពី ៥ គ.ម ពីសាលាឃុំ សង្កាត់ ឬនៅទីតាំងស្មុគ្រស្មាញដែលប្រជាពលរដ្ឋពិបាកធ្វើដំណើរមកចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ។ ការិយាល័យទាំងនេះប្រើរយៈពេលមិនឱ្យលើសពីមួយភាគពីរ(១/២)នៃរយៈពេលសរុប ។
- ក្រុមប្រឹក្សា និងស្មៀនឃុំ សង្កាត់ អាចកែសម្រួលរយៈពេលខាងលើនេះតាមការចាំបាច់ និងតាមសភាពជាក់ស្តែងហើយត្រូវជូនដំណឹងដល់ប្រធានភូមិ ប្រជាពលរដ្ឋ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាមុន ។
- ការិយាល័យបោះឆ្នោតមួយ គិតទាំងការិយាល័យបោះឆ្នោតបង្កើតថ្មីផង ត្រូវទទួលចុះឈ្មោះអ្នកបោះឆ្នោតយ៉ាងច្រើនបំផុតត្រឹមចំនួនប្រាំពីររយ(៧០០)នាក់ ។

#### ខ- រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់

- ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ ចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ។
- ស្មៀនឃុំ សង្កាត់ត្រូវធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជារៀងរាល់ថ្ងៃគិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ។ ម៉ោងពេលធ្វើការត្រូវបានកំណត់ :
  - ពេលព្រឹកចាប់ពីម៉ោងប្រាំពីរ(៧:០០) ដល់ម៉ោងដប់មួយសាមសិប(១១:៣០)នាទី
  - ពេលរសៀលចាប់ពីម៉ោងដប់បួន(១៤:០០)នាទី ដល់ម៉ោងដប់ប្រាំពីរសាមសិបនាទី (១៧:៣០) ។

- ក្នុងករណីមានអ្នកសុំចុះឈ្មោះបន្តទៀត កបឃ/ស ស្មៀនឃុំ សង្កាត់ អាចបន្ថែមម៉ោងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការចាំបាច់ ។
- ទោះបីកំពុងអនុវត្តតាមប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋតាមការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយក៏ដោយ ក៏ស្មៀនឃុំ សង្កាត់ត្រូវទទួលចុះឈ្មោះជូនប្រជាពលរដ្ឋដែលអញ្ជើញមកពីភូមិនានាផ្សេងទៀតនៃឃុំ សង្កាត់របស់ខ្លួនដែរ ។

**គ- គំនូសតាងស្តីពីពេលវេលាសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២នេះ មានរយៈពេល៤២ថ្ងៃតាមគំនូសតាងដូចខាងក្រោម ៖




**ចំណាំ :**

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការ និងស្មៀន អាចបន្ថែមពេលម៉ោងធ្វើការបានបន្ទាប់ពីបញ្ចប់ម៉ោងធ្វើការទាំងពេលព្រឹក ឬ/និងពេលរសៀល ប្រសិនបើនៅមានអ្នកសុំចុះឈ្មោះ ។
- ថ្ងៃទី ២៤ ខែកញ្ញា ទិវាប្រកាសរដ្ឋធម្មនុញ្ញ ធ្វើការធម្មតា តែមិនរាប់បញ្ចូលក្នុងរយៈពេលនៃការប្តឹង ឬដោះស្រាយបណ្តឹងឡើយ ។

**២. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត និងការផ្សព្វផ្សាយអំពីកាលបរិច្ឆេទនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

- កបឃ/ស និងស្មៀនត្រូវបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ និងនៅទីកន្លែងណាមួយក្នុងឃុំ សង្កាត់យ៉ាងតិច ១០ថ្ងៃមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត (បិទនៅថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១២) ។
- កបឃ/ស និងស្មៀនត្រូវកំណត់ និងផ្សព្វផ្សាយជាសាធារណៈពីរយៈពេល កាលបរិច្ឆេទ និងប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងរយៈពេលយ៉ាងតិចបី(៣)ថ្ងៃ មុនថ្ងៃចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

**៣. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់)**

**ក- បរិវេណខាងក្នុង**

បរិវេណខាងក្នុងជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអគារដែលការិយាល័យចុះឈ្មោះបោះឆ្នោតតាំងនៅ ។ បរិវេណនេះខណ្ឌដោយរង្វង់មណ្ឌលមួយដែលមានកាំប្រវែងយ៉ាងតិចដប់ប្រាំ(១៥)ម៉ែត្រ ឬតាមស្ថានភាពទីតាំងជាក់ស្តែង ។

**ខ- បរិវេណខាងក្រៅ**

បរិវេណខាងក្រៅជាតំបន់ព័ទ្ធជុំវិញការិយាល័យចុះឈ្មោះបោះឆ្នោតដែលខណ្ឌដោយរង្វង់មណ្ឌល មានកាំប្រវែងមួយរយ(១០០)ម៉ែត្រ ឬតូចជាងអាស្រ័យទៅតាមស្ថានភាពទីតាំងជាក់ស្តែង ឬមាន ទម្រង់ផ្សេងពីនេះ ដូចជារបងវត្ត សាលារៀន សាលមហោស្រព ឬទីធ្លាសាធារណៈជាដើម ។

នៅតំបន់ដែលមានបញ្ហាសន្តិសុខអាចរំខានដល់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ បោះឆ្នោត បរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានកំណត់ដោយ កបឃ/ស និង ស្មៀនដោយយោងលើការវាយតម្លៃអំពីស្ថានភាពភូមិសាស្ត្រ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងតំបន់នោះ ។

**៤. សន្តិសុខ**

**ក- បម្រាមយកអាវុធជាតិផ្ទុះចូលការិយាល័យចុះឈ្មោះបោះឆ្នោត**

ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ ឬសារជាតិ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូល ក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។ ស្មៀនឃុំ សង្កាត់ មានសិទ្ធិអំណាចពេញលេញក្នុងការទាក់ទងស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ប្រសិនបើ មានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះ បោះឆ្នោត ។ ក្នុងករណីនេះភ្នាក់ងារសន្តិសុខដែលមានបំពាក់អាវុធសមស្របអាចចូលធ្វើអន្តរាគមន៍ បានក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។

**ខ- បម្រាមចូលការិយាល័យចុះឈ្មោះបោះឆ្នោត**

នាយ ឬពលនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងនគរបាលជាតិពុំអាច ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឬឈរជិតបរិវេណការពារសន្តិសុខបានទេ ប្រសិនបើពួកគាត់ មិនទៅចុះឈ្មោះបោះឆ្នោត ឬមិនបានទទួលភារកិច្ចជាភ្នាក់ងារសន្តិសុខ ឬភ្នាក់ងារសង្គ្រោះ ។

ហាមជនគ្រប់រូបចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត មុនពេលការិយាល័យចាប់ផ្តើមធ្វើការ និង ក្រោយពេលការិយាល័យបិទទ្វារ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ ក្នុងករណី ចាំបាច់បម្រាមនេះត្រូវអនុវត្តលើបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ។

**គ- ការអនុញ្ញាតឱ្យចូលការិយាល័យចុះឈ្មោះបោះឆ្នោត**

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំង ឡាយដូចខាងក្រោម ៖

- ស្មៀនឃុំ សង្កាត់ ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត ។
- សមាជិក កបឃ/ស ដែលប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ក្នុងការពិនិត្យ បញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មានដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប ។
- តំណាងគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ ហើយ ដែលត្រូវបានអនុញ្ញាតដោយ កបឃ/ស ។

- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងចុះឈ្មោះបោះឆ្នោត ហើយដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតនៅឡើយ ។
- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយក្នុងឃុំ សង្កាត់រួចហើយ ប៉ុន្តែមានបំណងសុំកែតម្រូវឈ្មោះ ឬទិន្នន័យពាក់ព័ន្ធដែលសរសេរខុស ។
- នីតិជនអមដំណើរអ្នកសុំចុះឈ្មោះបោះឆ្នោត ដែលជាជនពិការមិនអាចសុំចុះឈ្មោះបានដោយខ្លួនឯង ។
- ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលស្មៀនឃុំ សង្កាត់ស្នើសុំក្នុងករណីចាំបាច់ ។

**ឃ- សកម្មភាពដែលត្រូវហាមឃាត់**

សកម្មភាពទាំងឡាយដែលត្រូវហាមឃាត់ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

- ការស្លៀកពាក់ ឬបិទផ្សាយ ឬការនិយាយពាក់ព័ន្ធនឹងគណបក្សនយោបាយ ។
- ការបង្ហាញការគាំទ្រ ឬការប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ។
- ការរំខាន ឬសកម្មភាពផ្សេងៗដែលអាចមានឥទ្ធិពលដល់ជនណាម្នាក់ក្នុងការចុះឈ្មោះបោះឆ្នោត ។

## II. ការធ្វើប្រតិភូកម្មអំណាចដល់ កបឃ/ស

គ.ជ.ប ត្រូវប្រគល់សិទ្ធិអំណាចឱ្យ កបឃ/ស បំពេញតួនាទីជាតំណាងរបស់ខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថា បានលើកសំណើសុំទៅ គ.ជ.ប តែងតាំងស្មៀនឃុំ សង្កាត់ ឱ្យទទួលបន្ទុកជាមន្ត្រីពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ និងបានតែងតាំងសមាជិក កបឃ/ស តាមការកំណត់នៃច្បាប់ឱ្យប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀន ។

### ១. តួនាទី និងភារកិច្ចរបស់ កបឃ/ស

**ក- ការធានាការអនុវត្តសិទ្ធិអំណាចដែល គ.ជ.ប បានធ្វើប្រតិភូកម្មឱ្យ**

កបឃ/ស ត្រូវ ៖

- ចាត់សមាជិកតាមចំនួនដែលកំណត់ដោយច្បាប់ ឱ្យប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- លើកសំណើជូន គ.ជ.ប ពិនិត្យតែងតាំងមន្ត្រីចុះឈ្មោះបោះឆ្នោតថ្មី សម្រាប់ជំនួសស្មៀនដែលមិនអាចមកបំពេញការងារបានក្រោយពីបានតែងតាំងហើយ ។
- ទទួលពាក្យស្នើសុំ និងសម្រេចចុះឈ្មោះតំណាងគណបក្សនយោបាយ ចូលរួមសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។
- ទទួលបន្ទុកអប់រំ ផ្សព្វផ្សាយ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋកំពុងរស់នៅក្នុងឃុំ សង្កាត់ បានទៅពិនិត្យផ្ទៀងផ្ទាត់មើលឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ និងបញ្ជីបោះឆ្នោតដំបូង ឬចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅសាលាឃុំ សង្កាត់ និងនៅតាមភូមិ ។

- ចេញលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បម្រើឱ្យការបោះឆ្នោតជូនប្រជាពលរដ្ឋ (បើគាត់ស្នើសុំ) និងធ្វើរបាយការណ៍សរុបអំពីការចេញលិខិតនេះ រួចផ្ញើជូនក្រសួងមហាផ្ទៃ និងផ្ញើជូន គ.ជ.ប តាមឋានានុក្រម ដោយអនុវត្តតាមសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប លេខ ០២៣ សណន ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ ។
- ធានាផ្តល់ជំនួយសមស្របចំពោះជនពិការដែលមិនអាចពិនិត្យបញ្ជីឈ្មោះ ឬសុំចុះឈ្មោះបោះឆ្នោត បានដោយខ្លួនឯង និងដែលបានស្នើសុំជំនួយ ។
- ចាត់វិធានការសមស្របដើម្បីធានាថា រាល់កិច្ចប្រតិបត្តិការទាក់ទងដល់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង ។
- ចាត់ចែងដោះស្រាយឱ្យមានអន្តរាគមន៍ពីកម្លាំងនគរបាល ឬកម្លាំងមានសមត្ថកិច្ចតាមសំណើរបស់ស្មៀនឃុំ សង្កាត់ ក្នុងករណីដែលមានជនណាបង្កការអុកឡុករំខាន គំរាមកំហែង ឬប្រព្រឹត្តអំពើល្មើសច្បាប់ សំដៅបង្អាក់ដំណើរនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- រាយការណ៍ជូន គ.ជ.ប តាមរយៈ លធ/ខប នូវរាល់ហេតុការណ៍ដែលអាចកើតមានក្នុងដំណើរនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហា ។
- ទទួល និងដោះស្រាយ ដោយបើកការប្រជុំសម្រេចជាសាធារណៈ នូវរាល់បណ្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត និងបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទាក់ទងនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។
- ផ្ញើជូន គ.ជ.ប នូវរាល់សម្រង់សេចក្តីសម្រេចរបស់ខ្លួន ទ.១២០៣ និងផ្តល់ ទ.១២០២ សម្រាប់បំពេញពាក្យប្តឹងតវ៉ា ឬពាក្យប្តឹងជំទាស់តាមសំណើសុំរបស់អ្នកប្តឹង ឬតំណាង ។
- ជួយដល់ស្មៀនឃុំ សង្កាត់ក្នុងការផ្ទៀងផ្ទាត់ ការបូកសរុប ការរៀបចំវេចខ្ចប់ និងការបញ្ជូនលទ្ធផល និងសម្ភារៈ ឯកសារចុះឈ្មោះបោះឆ្នោតជូន គ.ជ.ប តាមរយៈ លធ/ខប ។

**ខ- ការចាត់តាំងសមាជិក កបឃ/ស ឱ្យប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់**

- ក្នុងករណី កបឃ/ស មានសមាជិកប្រាំ(៥)រូប ត្រូវចាត់តាំងសមាជិកមួយ (១)រូប ។ ក្នុងករណី កបឃ/ស មានសមាជិកប្រាំពីរ(៧)រូបឡើងទៅត្រូវចាត់តាំងសមាជិកពីរ(២)រូប ។
- កបឃ/ស អាចផ្លាស់ប្តូរសមាសភាពសមាជិកក្រុមប្រឹក្សា ដែលត្រូវប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដោយផ្អែកលើសំណូមពរការងារចាំបាច់របស់ខ្លួន និងសំណូមពរការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។ សមាជិក កបឃ/ស ដែលបានតែងតាំង ឬផ្លាស់ប្តូរឱ្យប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតត្រូវតែបានទទួលការបណ្តុះបណ្តាល និងមានការយល់ដឹងច្បាស់លាស់ដែលអាចបំពេញការងារពិនិត្យមើលការខុសត្រូវបានល្អ ប៉ុន្តែពុំទទួលបានប្រាក់កម្រៃឡើយ ។

- កបឃ/ស ត្រូវរាយការណ៍អំពីសមាសភាពសមាជិករបស់ខ្លួនដែលបានតែងតាំង ឬផ្លាស់ប្តូរឱ្យប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនជូន គ.ជ.ប ជាព័ត៌មាន ។
- កបឃ/ស ត្រូវផ្តល់យោបល់ដល់ស្មៀនឃុំ សង្កាត់ក្នុងការកំណត់ប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតនានាក្នុងឃុំ សង្កាត់ ។
- សមាជិក កបឃ/ស ដែលទទួលតួនាទីប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ពេលចុះតាមភូមិគួរតែជាមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលបានទទួលសិទ្ធិ ដើម្បីចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតជូនដល់អ្នកសុំចុះឈ្មោះដែលបានស្នើសុំ និងសហការជាមួយប្រធានភូមិនានាក្នុងឃុំ សង្កាត់ខ្លួន ចាត់ចែងឱ្យប្រជាពលរដ្ឋមកមើលឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមលំដាប់លំដោយមុនក្រោយជាហូរហែ និងគ្មានការកកស្ទះ ហើយត្រូវ ៖
    - ជូនយោបល់ដល់ស្មៀន ក្នុងករណីមានការសុំយោបល់ពីស្មៀនពាក់ព័ន្ធនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតណាមួយ ។
    - ណែនាំរំលឹកស្មៀនអំពីផ្នែក ឬចំណុចណាមួយដែលស្មៀនមិនបានអនុវត្ត ឬអនុវត្តខុស ។
    - រាយការណ៍ជាបន្ទាន់ទៅ កបឃ/ស និង គ.ជ.ប ប្រសិនបើការអនុវត្តការងាររបស់ស្មៀនឃុំ សង្កាត់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ។
    - រាយការណ៍ជាប្រចាំជូន កបឃ/ស អំពីភាពជឿនលឿននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

**គ- ការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងចាត់ចែងសន្តិសុខ**

កម្លាំងរក្សាសណ្តាប់ធ្នាប់ ៖

- មិនត្រូវបានបំពាក់អាវុធទេ ។
- ត្រូវដាក់ឱ្យស្ថិតនៅក្រោមការណែនាំរបស់ស្មៀនឃុំ សង្កាត់ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោត ។
- ត្រូវទទួលភារកិច្ចសម្រួលសណ្តាប់ធ្នាប់សម្រាប់ប្រជាពលរដ្ឋដែលចូលមកកាន់ការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីសុំចុះឈ្មោះបោះឆ្នោត ។
- ត្រូវធានាយ៉ាងណាឱ្យមានអ្នកសុំចុះឈ្មោះបោះឆ្នោតយ៉ាងច្រើនត្រឹមបី(៣)នាក់ ក្នុងពេលតែមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។ នៅពេលអ្នកសុំចុះឈ្មោះម្នាក់ចេញពីការិយាល័យទើបអនុញ្ញាតឱ្យម្នាក់ទៀតចូល ។
- ត្រូវផ្តល់អាទិភាពចំពោះព្រះសង្ឃ ជនចាស់ជរា អ្នកមានជំងឺ ស្ត្រីមានផ្ទៃពោះ និងជនពិការចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។
- ត្រូវអនុញ្ញាតឱ្យអ្នកជំនួយជានីតិជនម្នាក់ជូនដំណើរជនពិការដែលមិនអាចសុំចុះឈ្មោះបោះឆ្នោតបានដោយខ្លួនឯង ចូលការិយាល័យចុះឈ្មោះបោះឆ្នោត ។
- ត្រូវរាយការណ៍ជាបន្ទាន់ជូនស្មៀនឃុំ សង្កាត់ ក្នុងករណីមានការអុកឡុករំខានពីជនណាម្នាក់ ដើម្បីមានវិធានការស្នើសុំកិច្ចអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬ/និងអាជ្ញាធរមានសមត្ថកិច្ច ។

## ២. ភារកិច្ចរបស់មន្ត្រីចុះឈ្មោះបោះឆ្នោត

### ក- សេចក្តីណែនាំទូទៅសម្រាប់ស្មៀនឃុំ សង្កាត់

ស្មៀនឃុំ សង្កាត់ត្រូវ ៖

- ទទួលខុសត្រូវអនុវត្តរាល់កិច្ចប្រតិបត្តិការបម្រើឱ្យគោលបំណងនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។
- គោរព ច.ប.ត.រ និង ប.ន.ត.រ ។
- ប្រកាន់ជំហរអព្យាក្រឹត និងមិនលំអៀងក្នុងពេលបំពេញការងារ ។
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- យល់ដឹងឱ្យបានត្រឹមត្រូវ និងម្ចាស់ការបានលើរាល់នីតិវិធីពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- ចេះចាត់វិធានការចាំបាច់នានា ដើម្បីធានាឱ្យជនគ្រប់រូបបានចូលរួមប្រកបដោយសុវត្ថិភាព គ្មានការភ័យខ្លាច ឬការបំភិតបំភ័យក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនទទួលខុសត្រូវ សំដៅធ្វើឱ្យការងារនេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព ។
- ចេះបំពេញទម្រង់បែបបទពាក់ព័ន្ធផ្សេងៗ ដែលបានកំណត់ និងចេះធ្វើរបាយការណ៍បានច្បាស់លាស់ ។

### ខ- ការទទួលខុសត្រូវ និងភារកិច្ចរបស់ស្មៀនឃុំ សង្កាត់

ស្មៀនឃុំ សង្កាត់ត្រូវ ៖

- សហការយ៉ាងជិតស្និទ្ធជាមួយមេភូមិ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ក្នុងការចុះស្រាវជ្រាវជាក់ស្តែងនៅតាមភូមិ ដើម្បីស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបានទទួលមរណភាព អ្នកផ្លាស់ប្តូរទីលំនៅចេញក្រៅឃុំ សង្កាត់ ឬគ្មានទីលំនៅក្នុងឃុំ សង្កាត់ ឬមានឈ្មោះស្ទួនក្នុងឃុំ សង្កាត់ដោយភ្ជាប់ឯកសារភស្តុតាងសម្រាប់ដាក់ជូន កបឃ/ស ពិនិត្យសម្រេចលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- បំពេញរាល់ការងារត្រៀមសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដូចជាការស្រង់ស្ថិតិប្រជាពលរដ្ឋ ការស្រង់ឈ្មោះអ្នកដែលត្រូវចុះឈ្មោះបោះឆ្នោត ការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោតនៅក្នុងឃុំ សង្កាត់របស់ខ្លួនតាម ច.ប.ត.រ នីតិវិធី និងសេចក្តីណែនាំរបស់ គ.ជ.ប ។
- ធានាឱ្យអ្នកសង្កេតការណ៍ និងតំណាងគណបក្សនយោបាយដែលមានការបញ្ជាក់ទទួលស្គាល់ មានលទ្ធភាពសង្កេតការណ៍ក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅគ្រប់ការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។
- សុំកិច្ចអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬអាជ្ញាធរមានសមត្ថកិច្ចឱ្យនាំខ្លួនជនទាំងឡាយណាដែលបង្កការអុកឡុករំខាន ឬធ្វើសកម្មភាពផ្ទុយពីការកំណត់របស់ ច.ប.ត.រ និង ប.ន.ត.រ ក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- សំណូមពរភ្នាក់ងារសង្គ្រោះឱ្យជួយដល់ជនទាំងឡាយណា ដែលទទួលរងគ្រោះដោយមូលហេតុណាមួយក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។

- ត្រួតពិនិត្យ ចុះវត្តមានតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានការបញ្ជាក់ទទួលស្គាល់រួចហើយ ។
- ត្រួតពិនិត្យ គ្រប់គ្រង និងអនុវត្តដោយផ្ទាល់នូវរាល់ការងារ និងជំហាននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- អនុវត្តការងារដទៃទៀត ដែលតម្រូវដោយ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

**ខ.១- មុនពេលចុះឈ្មោះបោះឆ្នោត**

- បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត ។
- បិទផ្សាយ ឬ/និងផ្សព្វផ្សាយរាល់ឯកសារអប់រំសាធារណជន ។
- ផ្សព្វផ្សាយប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- ធ្វើគំរូប្លង់ និងធានាថាការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានសំអាត និងថែរក្សាសុវត្ថិភាពបានល្អ ។
- ត្រួតពិនិត្យ និងគ្រប់គ្រងបរិមាណ និងគុណភាពសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត ។
- ថែរក្សាសុវត្ថិភាពសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត ។
- បិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយមួយច្បាប់ៗនៅសាលាឃុំ សង្កាត់ ។
- លើក ឬចងស្លាកការិយាល័យចុះឈ្មោះបោះឆ្នោត ។

**ខ.២- ក្នុងពេលចុះឈ្មោះបោះឆ្នោត**

- ទទួលធ្វើសម្ភាសន៍អ្នកសុំចុះឈ្មោះបោះឆ្នោត និងពិនិត្យឯកសារភស្តុតាងបញ្ជាក់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោតដែលអ្នកសុំចុះឈ្មោះបានបង្ហាញព្រមទាំងធ្វើការសម្រេចយល់ព្រមចុះឈ្មោះជូនអ្នកសុំចុះឈ្មោះពាក់ព័ន្ធ ។ ក្នុងករណីបដិសេធការសុំចុះឈ្មោះរបស់ជនណាម្នាក់ ស្មៀនឃុំ សង្កាត់ត្រូវសួរយោបល់សមាជិក កបយ/ស ដែលប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ ។ បើសមាជិក កបយ/ស មានមួយ(១)នាក់ ស្មៀនត្រូវយកតាមយោបល់របស់សមាជិក កបយ/ស ។ បើសមាជិក កបយ/ស មានពីរ(២)នាក់ ស្មៀនត្រូវយកតាមយោបល់ភាគច្រើនក្នុងចំណោមសមាជិកទាំងពីរ(២)នាក់ និងស្មៀន ។
- បំពេញ និងចុះលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកសុំចុះឈ្មោះ(បើមាន)ទៅក្នុងគល់បញ្ជី និងចុងសន្លឹកបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត រួចហែកចុងសន្លឹកបង្កាន់ដៃជូនគាត់ ។
- សរសេរឈ្មោះរបស់អ្នកដែលត្រូវបានយល់ព្រមឱ្យចុះឈ្មោះ និងទិន្នន័យពាក់ព័ន្ធទៅក្នុងបញ្ជីបោះឆ្នោតបន្ថែម ដោយចម្លងចេញពីទម្រង់បែបបទចុះឈ្មោះបោះឆ្នោត ។ ក្នុងនោះត្រូវកត់ត្រាលេខរៀងទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតផង ។
- បំពេញ និងចុះលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកសុំកែតម្រូវ(បើមាន) ទៅក្នុងគល់បញ្ជី និងចុងសន្លឹកបង្កាន់ដៃទទួលកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត(ទ.១០២៨) និងឱ្យគាត់ផ្តិតមេដៃលើគល់បញ្ជី និងចុងសន្លឹកបង្កាន់ដៃបញ្ជាក់ការសុំកែតម្រូវ រួចហែកចុងសន្លឹកបង្កាន់ដៃជូនគាត់ ។

- ជម្រាបអ្នកចុះឈ្មោះ ឬអ្នកសុំកែតម្រូវឱ្យរក្សាបង្កាន់ដៃ ចាំលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត សម្រាប់មើលឈ្មោះនៅពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។
- បំពេញទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោតចំពោះអ្នកដែលមិនបានឆ្លើយតបគ្រប់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ។ ជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេលបី(៣) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចបដិសេធ ។
- ផ្តល់ ទ.១២០២ ចំនួន បី ( ៣ ) ច្បាប់ ជូនអ្នកប្តឹងដើម្បីបំពេញ ប្រសិនបើគាត់ស្នើសុំ ។
- លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ក្នុងករណីអ្នកបោះឆ្នោតនោះស្លាប់ ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាល ឬស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬផ្លាស់ទីលំនៅចេញ ឬគ្មានទីលំនៅក្នុងឃុំ សង្កាត់ ឬមានឈ្មោះស្ទួន ឬជាជនអន្តោប្រវេសន៍ ក្នុងករណីមានភស្តុតាង ឬមានឯកសារផ្លូវការទាក់ទងនឹងអ្នកដែលត្រូវលុប ។
- បំពេញ ទ.១០១៦ សម្រាប់លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ករណីស្លាប់ ឬបាត់បង់សិទ្ធិ ឬផ្លាស់ចេញ ឬគ្មានទីលំនៅអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នក្នុងឃុំ សង្កាត់) ។
- បំពេញ ទ.១០១៧ សម្រាប់លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត (ករណីប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់តែមួយ ឬផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់ ឬឈ្មោះស្ទួន) ។
- ធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតចុងក្រោយ ។
- ថែរក្សាទុកជាឯកសារនូវរាល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត រាល់ទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត រាល់សេចក្តីសម្រេចលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ និងឯកសារពាក់ព័ន្ធផ្សេងទៀតមួយមុខមួយច្បាប់ៗ ។
- ធានាថាបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់មានអ្នកបោះឆ្នោតមិនលើសពីប្រាំពីររយ(៧០០)នាក់ ហើយត្រូវយកចិត្តទុកដាក់ចុះឈ្មោះបោះឆ្នោតចំពោះការិយាល័យបោះឆ្នោតដែលមានចំនួនអ្នកបោះឆ្នោតតិច និងការិយាល័យបោះឆ្នោតបង្កើតថ្មី (ប្រសិនបើមាន) ។
- ដោះស្រាយជាបន្ទាន់នូវរាល់ការតវ៉ា និងការជំទាស់ចំពោះការរំលោភនានានៅក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលអាចលើកឡើងដោយសមាជិក កបឃ/ស ដែលប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ ឬតំណាងគណបក្សនយោបាយ ។

### ខ.៣- ការធ្វើរបាយការណ៍

- ធ្វើរបាយការណ៍ផ្ទៀងផ្ទាត់លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ ។
- ធ្វើរបាយការណ៍លទ្ធផល(ទ.១០១១) សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ និងរបាយការណ៍សរុបលទ្ធផល(ទ.១០១២)សម្រាប់ឃុំ សង្កាត់ទាំងមូលនៅពេលដែលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ ។

- ធ្វើរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បែបបទចុះឈ្មោះបោះឆ្នោត/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដោយប្រើ ទ.១០២១ ។
- ធ្វើរបាយការណ៍កែតម្រូវលើបញ្ជីបោះឆ្នោតដំបូង ដោយប្រើទ.១០២០ និងតារាងភ្ជាប់ជាមួយ ។

**ខ.៤- ក្រោយពេលចុះឈ្មោះបោះឆ្នោត**

- ផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតចុងក្រោយដែលធ្វើបច្ចុប្បន្នភាពរួច បញ្ជីបោះឆ្នោតបន្ថែម រួចផ្គុំបញ្ចូលគ្នាតាមការិយាល័យបោះឆ្នោតពាក់ព័ន្ធនីមួយៗ ផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតបង្កើតថ្មី រួចធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត( ទ.១០១១) ។
- ថតចម្លង ឬស្នើសុំ លធ/ខប ឱ្យថតចម្លងបញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពរួច និងបញ្ជីបោះឆ្នោតបន្ថែម ឬ/និងបញ្ជីបោះឆ្នោតនៃការិយាល័យបង្កើតថ្មី ។
- បិទផ្សាយបញ្ជីបោះឆ្នោតដំបូងមួយ (១) ច្បាប់ៗនៅសាលាឃុំ សង្កាត់ ។
- បិទផ្សាយបញ្ជីបោះឆ្នោតដំបូងមួយ (១) ច្បាប់ៗនៅតាមទីតាំងណាមួយក្នុងឃុំ សង្កាត់ ។
- ផ្ទៀងផ្ទាត់ និងវេចខ្ចប់ដោយឡែកតាមការិយាល័យនីមួយៗ និងបញ្ជូនបញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួច រួមទាំងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតបង្កើតថ្មី និងសម្ភារៈឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោតមក គ.ជ.ប តាមរយៈ លធ/ខប ។
- ចូលរួមបំភ្លឺក្នុងរាល់ការប្រជុំសម្រេចជាសាធារណៈរបស់ កបឃ/ស ដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ។

**៣. ការប្រើប្រាស់បញ្ជីបោះឆ្នោតចុងក្រោយឆ្នាំ២០១១**

បញ្ជីបោះឆ្នោតចុងក្រោយ = ៣ច្បាប់

- ១ ច្បាប់ បិទផ្សាយនៅសាលាឃុំ សង្កាត់ នៅថ្ងៃទី៣០-៣១ ខែសីហា ឆ្នាំ២០១២ ។
- ១ ច្បាប់ ទុកប្រើប្រាស់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- ១ ច្បាប់ បិទផ្សាយនៅមុខការិយាល័យចល័តតាមភូមិ ។

**ចំណាំ :**

☛ មិនត្រូវចុះឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនីមួយៗ រួមទាំងការិយាល័យទើបបង្កើតថ្មីផង ឱ្យលើសពីប្រាំពីររយ (៧០០)នាក់ ឡើយ ។

# គំនូសបំព្រួញសកម្មភាពពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត

## កម្លាំងរក្សាសណ្តាប់ធ្នាប់

- សុំឱ្យអ្នកសុំចុះឈ្មោះបង្ហាញឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ។
- ធានាឱ្យមានអ្នកសុំចុះឈ្មោះយ៉ាងច្រើន ៣ នាក់ ក្នុងពេលតែមួយក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។
- ផ្តល់អាទិភាពចំពោះព្រះសង្ឃ ជនចាស់ជរា អ្នកមានជំងឺ ស្ត្រីមានផ្ទៃពោះ និងជនពិការចូលក្នុងការិយាល័យ ។
- អនុញ្ញាតឱ្យនីតិជនមួយ(១)នាក់ បានអមដំណើរជនពិការ ដែលពុំអាចសុំចុះឈ្មោះដោយខ្លួនឯង ។

## ស្មៀនឃុំ សង្កាត់

- ពិនិត្យអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ចូលក្នុងការិយាល័យ ។
- ពិនិត្យកែតម្រូវឈ្មោះ ឬ/និងទិន្នន័យតាមការស្នើសុំរបស់អ្នកបោះឆ្នោត និងចេញបង្កាន់ដៃទទួលកែតម្រូវ (ទ.១០២៨) ដោយត្រូវចុះលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់គាត់ (បើមាន) នៅលើផ្នែកទាំងពីរ(២) និងឱ្យអ្នកស្នើសុំផ្តិតមេដៃលើគល់បញ្ជី និងចុងសន្លឹកបង្កាន់ដៃបញ្ជាក់ការសុំកែតម្រូវ ។
- ទទួលធ្វើសម្ភាសន៍អ្នកសុំចុះឈ្មោះបោះឆ្នោត និងពិនិត្យភស្តុតាងបញ្ជាក់លក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោត ។
- សម្រេចយល់ព្រមចុះឈ្មោះបោះឆ្នោតជូនអ្នកសុំចុះឈ្មោះ ដែលមានឯកសារបញ្ជាក់លក្ខខណ្ឌគ្រប់គ្រាន់ដោយ ៖
  - បំពេញទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃ ដោយត្រូវចុះលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់គាត់ (បើមាន) នៅលើផ្នែកទាំងពីរ(២) រួចហែកចុងសន្លឹកបង្កាន់ដៃជូនអ្នកសុំចុះឈ្មោះ ។
  - បំពេញទិន្នន័យភ្លាមក្នុងទម្រង់បែបបទបញ្ជីបោះឆ្នោតបន្ថែម (ទ.១០២៣) ។
- សម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត យោងតាមយោបល់សមាជិក កបឃ/ស ឬយោបល់ភាគច្រើន ដោយបំពេញ ទ.១០០៩ ចំនួន ៣ ច្បាប់ រួចជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធ ១ ច្បាប់ ។
- ជូន ទ.១២០២ ចំនួន ៣ ច្បាប់ ទៅអ្នកប្តឹងតវ៉ា (តាមសំណើសុំ) ។
- បំពេញទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ទ.១០១៦ ឬ ទ.១០១៧ ។
- គូសលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោតក្នុងករណីមានភស្តុតាង ឬ/និងឯកសារផ្លូវការ ។
- សុំកិច្ចអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬអាជ្ញាធរមានសមត្ថកិច្ចឱ្យនាំជនបង្កការអុកឡុករំខានចេញពីការិយាល័យចុះឈ្មោះបោះឆ្នោត ។
- ធ្វើរបាយការណ៍ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ ។

## សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការ

- ផ្តល់យោបល់ដល់ស្មៀនក្នុងការបដិសេធការសុំចុះឈ្មោះ ក្នុងករណីដែលស្មៀនសុំយោបល់ ។
- ណែនាំរំលឹកស្មៀនអំពីផ្នែក ឬចំណុចណាមួយដែលស្មៀនមិនបានអនុវត្ត ឬអនុវត្តខុស ច.ប.ត.រ និង ប.ន.ត.រ ។
- រាយការណ៍ជាបន្ទាន់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ និងទៅ គ.ជ.ប ក្នុងករណីស្មៀនអនុវត្តការងារមានភាពមិនប្រក្រតី ឬមានបញ្ហាធ្ងន់ធ្ងរ ។
- រាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សាឃុំ សង្កាត់ អំពីភាពជឿនលឿននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

***សូមអញ្ជើញបងប្អូនប្រជាពលរដ្ឋទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា***

**ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតចាប់ផ្តើមពីថ្ងៃទី០១ខែកញ្ញា ដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ នៅសាលាឃុំ សង្កាត់ ឬនៅតាមភូមិនានា**





## III. ដំណាក់កាលសង្ខេបនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

កបឃ/ស ស្មៀនឃុំ សង្កាត់ មេភូមិ តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងឃុំ សង្កាត់ ត្រូវជួយផ្សព្វផ្សាយបំផុស និងលើកទឹកចិត្តប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ ឱ្យមកពិនិត្យមើលឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

**អ្នកទៅពិនិត្យមើលឈ្មោះ** → ប្រជាពលរដ្ឋខ្មែររស់នៅក្នុងឃុំ សង្កាត់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយឆ្នាំ២០១១ →

- ឃើញឈ្មោះត្រឹមត្រូវ { កត់ចំណាំលេខកូដ និងទីតាំងការិយាល័យ ។
- ឃើញឈ្មោះ តែខុសអក្ខរាវិរុទ្ធ ឬទិន្នន័យមិនត្រឹមត្រូវ → ជួបស្មៀន ដើម្បីកែតម្រូវតាមឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការដែលយកមកបង្ហាញ ។
- ឃើញឈ្មោះ តែការិយាល័យនៅឆ្ងាយពីទីលំនៅ លើសពី ៥ គ.ម → ជួបស្មៀន ដើម្បីសុំប្ដូរការិយាល័យ ។
- មិនឃើញឈ្មោះ → ជួបស្មៀន ដើម្បីសុំឱ្យជួយរក បើពុំឃើញទើបសុំចុះឈ្មោះថ្មី ។
- ឃើញឈ្មោះស្ទួន → ជួបស្មៀន ដើម្បីសុំលុបឈ្មោះស្ទួនលើសចេញ ទុកតែឈ្មោះមួយគត់តាមសំណើសុំ ។

**អ្នកសុំចុះឈ្មោះ** →

- ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ទើបគ្រប់អាយុ ១៨ឆ្នាំ គិតដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ (កើតមុន ឬត្រឹមថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៥) ។
- ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោតហើយទើបបានផ្លាស់ទីលំនៅចូលមកពីឃុំ សង្កាត់ផ្សេងទោះបីធ្លាប់បានចុះឈ្មោះឬមិនធ្លាប់បានចុះឈ្មោះបោះឆ្នោតក៏ដោយ ។
- ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំសង្កាត់ តែពុំធ្លាប់បានចុះឈ្មោះបោះឆ្នោត ។

→ ជួបស្មៀន ដើម្បីសុំចុះឈ្មោះបោះឆ្នោត

**ចំណាំ :**

- ☛ អ្នកសុំចុះឈ្មោះត្រូវយកឯកសារណាមួយ ឬច្រើនភ្ជាប់មកជាមួយផង ដើម្បីបញ្ជាក់លក្ខខណ្ឌចុះឈ្មោះ ។
- ☛ អ្នកសុំចុះឈ្មោះថ្មីដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយឆ្នាំ២០១១ នៅឃុំ សង្កាត់ផ្សេង (អ្នកផ្លាស់ទីលំនៅចូល) ត្រូវយកបន្ថែមមកជាមួយនូវឯកសារ ឬ/និងភស្តុតាង ដើម្បីបញ្ជាក់ថាពិតជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងនោះប្រាកដមែន(បើមាន) ។
- ☛ ស្មៀនត្រូវយកចិត្តទុកដាក់ធ្វើសម្ភាសន៍ និងសួរព័ត៌មានអ្នកសុំចុះឈ្មោះបោះឆ្នោត អ្នកសុំកែតម្រូវទិន្នន័យ អ្នកសុំលុបឈ្មោះពីបញ្ជីបោះឆ្នោត និងអនុវត្តកិច្ចការបន្តតាមករណីនីមួយៗឱ្យបានត្រឹមត្រូវ ។

# IV. សិទ្ធិចុះឈ្មោះបោះឆ្នោត

## ១. លក្ខខណ្ឌដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត

ប្រជាពលរដ្ឋទាំងពីរភេទត្រូវ ៖

- មកបង្ហាញខ្លួននៅចំពោះមុខស្មៀនឃុំ សង្កាត់ ដើម្បីសុំចុះឈ្មោះបោះឆ្នោត និងត្រូវមានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការ ឬលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ។
- មានសញ្ជាតិខ្មែរ ។
- មានអាយុយ៉ាងតិច ១៨ ឆ្នាំ គិតមកដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ។
- មានទីលំនៅក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវបោះឆ្នោត ។ ទីលំនៅអាចជាអគារ ផ្ទះល្វែង បន្ទប់សំណង់ ឬផ្នែកមួយនៃសំណង់ ឬទីតាំងជាក់លាក់ណាមួយដែលគេអាចរកគាត់ឃើញជាធម្មតា ។

ប្រជាពលរដ្ឋទាំងពីរភេទមិនត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះបោះឆ្នោត ៖

- ជាជនស្ថិតនៅក្នុងស្ថានភាពជាប់ពន្ធនាគារ ។
- ជាជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ។
- ជាជនវិកលចរិត ឬជនស្ថិតនៅក្រោមអាណាព្យាបាល ។

**ចំណាំ :**

- ជនវិកលចរិត ឬជនស្ថិតនៅក្រោមអាណាព្យាបាល ត្រូវមានលិខិតបញ្ជាក់ ដែលចេញដោយមន្ទីរពេទ្យ ឬស្ថាប័នសុខាភិបាល ឬស្ថាប័នមានសមត្ថកិច្ច ។
- រាល់លិខិតបញ្ជាក់ខាងលើ ត្រូវតែជាទម្រង់បែបបទកំណត់ និងចេញដោយស្ថាប័នជំនាញ ។
- ប្រជាពលរដ្ឋខ្មែរម្នាក់ៗត្រូវមានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់ ។
- ប្រជាពលរដ្ឋខ្មែរដែលមានទីលំនៅច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសយកកន្លែងតែមួយគត់ ដើម្បីចុះឈ្មោះបោះឆ្នោត ។


ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

## ២. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល
- អត្តសញ្ញាណប័ណ្ណនគរបាលជាតិ
- អត្តសញ្ញាណប័ណ្ណកងយោធពលខេមរភូមិន្ទ
- ប័ណ្ណសំគាល់ខ្លួនចេញដោយក្រសួងស្ថាប័នរដ្ឋ
- លិខិតឆ្លងដែន
- ឆាយាគណៈមហានិកាយ
- សុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ
- សង្ឃដីកា
- សៀវភៅគ្រួសារ
- ប័ណ្ណសំគាល់គ្រួសារ
- សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត
- លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត
- លិខិតបញ្ជាក់ទីលំនៅ ( ទ. ១០១៩ )
- លិខិតបញ្ជាក់ថាជាប្រជាពលរដ្ឋខ្មែរ ដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជា
- លិខិតបញ្ជាក់ ឯកសារ ឬសេចក្តីសម្រេចស្ថាពររបស់តុលាការដែលបញ្ជាក់ថា ឪពុក ឬម្តាយរបស់ អ្នកសុំចុះឈ្មោះជាប្រជាពលរដ្ឋខ្មែរ និងឯកសារដែលបង្ហាញថា អ្នកសុំចុះឈ្មោះគឺជាកូនរបស់ឪពុកឬម្តាយនោះ ។
- ឯកសារជាផ្លូវការបង្ហាញថា អ្នកសុំចុះឈ្មោះកើតនៅក្នុងប្រទេសកម្ពុជា ហើយឪពុក និងម្តាយបរទេសរបស់ជននោះក៏កើត និងរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជាដែរ និងឯកសារជាផ្លូវការដែលបង្ហាញថាអ្នកសុំចុះឈ្មោះ គឺជាកូនរបស់ឪពុក និងម្តាយនោះ ។

**អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ**




**អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល**




**អត្តសញ្ញាណប័ណ្ណនគរបាលជាតិ**




**អត្តសញ្ញាណប័ណ្ណកងយោធពលខេមរភូមិន្ទ**



## ប័ណ្ណសម្គាល់ខ្លួនចេញដោយក្រសួងស្ថាប័នរដ្ឋ




## លិខិតឆ្លងដែន




## អាយាគណៈមហានិកាយ




## សុទ្ធិបត្រគណៈធម្មយុត្តិកនិកាយ




## សង្ឃដីកា




## សៀវភៅគ្រួសារ



**សំបុត្រកំណើត**



**លិខិតបញ្ជាក់ទីលំនៅ**



**លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត**



**ផ្នែកគល់បញ្ជី** **ផ្នែកចុងសន្លឹក**

### ៣. លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត

លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ត្រូវបានផលិតដោយ គ.ជ.ប ជាទម្រង់បោះពុម្ព ចងជាសៀវភៅបញ្ជី ដែលមាន ៖

- គល់បញ្ជី និងចុងសន្លឹក
- លេខរៀង
- ចំណុចផ្នែកបច្ចេកទេសបង្ការការក្លែងបន្លំ
- កន្លែងបិទរូបថតសាមីជន

លិខិតបញ្ជាក់អត្តសញ្ញាណនេះប្រើប្រាស់សម្រាប់បំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ឬ/និងបោះឆ្នោត ។

**ក- អ្នកមានសិទ្ធិចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត**

មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលត្រូវបានប្រគល់សិទ្ធិពីមេឃុំ ចៅសង្កាត់ក្នុងនាម កបឃ/ស គឺជាអ្នកមានសិទ្ធិចេញលិខិតនេះ ។

**ការចេញលិខិតបញ្ជាក់នេះមានពីរ (២)ដំណាក់កាល** ៖

- នៅក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត តាមការស្នើសុំរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ដែលពុំមានឯកសារបញ្ជាក់អត្តសញ្ញាណ អាយុ និងទីលំនៅក្នុងឃុំ សង្កាត់ ដើម្បីបំពេញលក្ខខណ្ឌសុំចុះឈ្មោះបោះឆ្នោត ។
- នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល នៅក្នុងរយៈពេលចាប់ពី គ.ជ.ប ផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត រហូតដល់ម៉ោង៥:៣០នាទីល្ងាចនៃថ្ងៃសុក្រចុងក្រោយមុនថ្ងៃបោះឆ្នោត តាមការស្នើសុំរបស់ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ប៉ុន្តែបានបាត់បង់ឯកសារបញ្ជាក់អត្តសញ្ញាណ ឬពុំមានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយសម្រាប់ប្រើក្នុងការបោះឆ្នោត ។

**ខ- ការស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត**

អ្នកស្នើសុំលិខិតត្រូវ ៖

- បង្ហាញខ្លួនផ្ទាល់នៅចំពោះមុខមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលត្រូវបានប្រគល់សិទ្ធិពីមេឃុំ ចៅសង្កាត់ ។
- ភ្ជាប់មកជាមួយនូវរូបថតរបស់ខ្លួនចំនួនពីរ(២)សន្លឹក ថតចំពីមុខ ឱ្យឃើញមុខ និងស្មា ។
- នាំសាក្សីទៅជាមួយចំនួនពីរ(២)រូបដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ដើម្បីធានាការស្នើសុំ របស់ខ្លួន ។ សាក្សីត្រូវមានលក្ខណសម្បត្តិ និងបំពេញលក្ខខណ្ឌដូចខាងក្រោម ៖
  - មានទីលំនៅក្នុងឃុំ សង្កាត់នោះ
  - យល់ព្រមបង្ហាញឯកសារផ្សេងៗដែលអាចសន្មតថា សាក្សីបានចុះឈ្មោះបោះឆ្នោតរួចហើយ ឬមានលក្ខណសម្បត្តិ និងបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់នោះ ។
  - យល់ព្រមផ្តិតមេដៃធានាអះអាងអំពីអត្តសញ្ញាណ អាយុ និងទីលំនៅក្នុងឃុំ សង្កាត់របស់អ្នកស្នើសុំលិខិតបញ្ជាក់នេះ ។
  - មិនមែនជាសមាជិក កបឃ/ស មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងស្មៀនឃុំ សង្កាត់ ។

**គ- ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត**

ករណីអ្នកស្នើសុំ និងសាក្សីផ្តល់ព័ត៌មាន និងការធានាអះអាងគ្រប់គ្រាន់ និងត្រឹមត្រូវ មេឃុំ ចៅសង្កាត់ត្រូវយល់ព្រមចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតជូនអ្នកស្នើសុំដោយត្រូវ ៖

- បំពេញទម្រង់លិខិតបញ្ជាក់នេះ នៅលើគល់បញ្ជីនិងចុងសន្លឹកនៃទម្រង់ ។
- ឱ្យអ្នកស្នើសុំ និងសាក្សីផ្តិតមេដៃ នៅលើគល់បញ្ជីនិងចុងសន្លឹកនៃទម្រង់ ។

- ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់នៅលើហត្ថលេខារបស់ខ្លួននៅលើគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ ។
- បោះត្រានៅលើផ្នែកពាក់កណ្ដាលខាងក្រោមនៃរូបថតរបស់អ្នកស្នើសុំ នៅលើគល់បញ្ជី និងចុងសន្លឹក និងបោះត្រាបន្ថែមនៅចំពាក់កណ្ដាលរវាងគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ ។
- ហែកផ្ដាច់ចុងសន្លឹកពីគល់បញ្ជីនៃទម្រង់ រួចប្រគល់ចុងសន្លឹកនៃទម្រង់ជូនអ្នកស្នើសុំ ដោយរក្សាទុកគល់បញ្ជីក្នុងសៀវភៅបញ្ជីនៃទម្រង់ ជាឯកសាររបស់ឃុំ សង្កាត់ ។

  ករណីអ្នកស្នើសុំ និងសាក្សីពុំបានផ្ដល់ព័ត៌មាន និងការធានាអះអាងគ្រប់គ្រាន់ និងត្រឹមត្រូវ មេឃុំ ចៅសង្កាត់ ត្រូវបដិសេធដោយផ្ទាល់មាត់លើការចេញលិខិតបញ្ជាក់ និងត្រូវណែនាំអ្នកស្នើសុំឱ្យបំពេញលក្ខខណ្ឌ និងព័ត៌មានឱ្យបានគ្រប់គ្រាន់និងត្រឹមត្រូវ ដើម្បីធ្វើការស្នើ សុំជាថ្មី ។

  ករណីបំពេញទម្រង់នេះខុស មេឃុំ ចៅសង្កាត់ត្រូវគូសខ្វែងលើគល់បញ្ជីនិងចុងសន្លឹកនៃទម្រង់ និងរក្សាទុកទាំងគល់បញ្ជីនិងចុងសន្លឹក នៅក្នុងសៀវភៅបញ្ជី ។

**ឃ- ការរក្សាសៀវភៅបញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត**

មេឃុំ ចៅសង្កាត់ ត្រូវរក្សាទុកសៀវភៅបញ្ជីឱ្យបានល្អនៅសាលាឃុំ សង្កាត់របស់ខ្លួនសម្រាប់ធ្វើការត្រួតពិនិត្យតាមការចាំបាច់ ។ សៀវភៅបញ្ជីដែលត្រូវរក្សាទុករួមមាន ៖

- សៀវភៅបញ្ជីដែលមិនទាន់បានប្រើប្រាស់
- សៀវភៅបញ្ជីដែលបានប្រើប្រាស់ខ្លះហើយ
- សៀវភៅបញ្ជីដែលបានប្រើប្រាស់អស់ហើយ និងនៅសល់តែគល់បញ្ជី គិតទាំងសន្លឹកទម្រង់ដែលបំពេញខុសផង(ប្រសិនបើមាន) ។

**ង- ការធ្វើរបាយការណ៍ស្ដីពីលទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតនៅពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោត**

ពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវធ្វើរបាយការណ៍អំពីការចេញលិខិតបញ្ជាក់នេះបួន(៤)ច្បាប់ ចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រាឃុំ សង្កាត់ ។

- **នៅសាលាឃុំ សង្កាត់**

មេឃុំ ចៅសង្កាត់ត្រូវប្រើប្រាស់របាយការណ៍នេះដូចខាងក្រោម ៖

- ទុកជាឯកសារមួយ(១)ច្បាប់
- បិទផ្សាយនៅសាលាឃុំ សង្កាត់មួយ(១)ច្បាប់
- ផ្ញើជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌមួយ(១)ច្បាប់
- ផ្ញើជូន លធ/ខប មួយ(១)ច្បាប់ ស្របពេលជាមួយគ្នានឹងការបញ្ជូនសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត ។

▪ **សាលាក្រុង ស្រុក ខណ្ឌ**

គណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវប៉ូកសរុបរបាយការណ៍នេះក្នុងក្រុង ស្រុក ខណ្ឌរបស់ខ្លួនចំនួនពីរ(២)ច្បាប់ ចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រាក្រុង ស្រុក ខណ្ឌ រួចត្រូវ ៖

- ទុកជាឯកសារមួយ(១)ច្បាប់
- ផ្ញើជូនគណៈអភិបាលរាជធានី ខេត្ត មួយ(១)ច្បាប់ ។

▪ **សាលារាជធានី ខេត្ត**

គណៈអភិបាលរាជធានី ខេត្តត្រូវប៉ូកសរុបរបាយការណ៍នេះក្នុងរាជធានី ខេត្តរបស់ខ្លួនចំនួនពីរ(២)ច្បាប់ ចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រារាជធានី ខេត្ត រួចត្រូវ ៖

- ទុកជាឯកសារមួយ(១)ច្បាប់
- ផ្ញើជូនក្រសួងមហាផ្ទៃ មួយ(១)ច្បាប់ ។

▪ **លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ/ខប)**

លធ/ខប ត្រូវប៉ូកសរុបរបាយការណ៍នេះក្នុងរាជធានី ខេត្តរបស់ខ្លួនចំនួនពីរ(២)ច្បាប់ ចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រា រួចត្រូវ ៖

- ទុកជាឯកសារមួយ(១)ច្បាប់
- ផ្ញើជូន គ.ជ.ប មួយ(១)ច្បាប់ ស្របពេលនឹងការបញ្ជូនសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោតទៅ គ.ជ.ប ។

**ច- ការធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតនៅមុនថ្ងៃបោះឆ្នោត**

ក្នុងឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកលនៅក្នុងរយៈពេលចាប់ពី គ.ជ.ប ផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតរហូតដល់ម៉ោង ៥:៣០នាទីល្ងាច នៃថ្ងៃសុក្រចុងក្រោយ មុនថ្ងៃបោះឆ្នោត មេឃុំ ចៅសង្កាត់ ត្រូវតែបញ្ឈប់ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ។

មេឃុំ ចៅសង្កាត់ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ អំពីការចេញលិខិតបញ្ជាក់នេះចំនួនប្រាំមួយ(៦)ច្បាប់ ចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រាឃុំ សង្កាត់ ។

▪ **នៅសាលាឃុំ សង្កាត់**

មេឃុំ ចៅសង្កាត់ត្រូវប្រើប្រាស់របាយការណ៍នេះដូចខាងក្រោម ៖

- ទុកជាឯកសារមួយ(១)ច្បាប់
- បិទផ្សាយនៅសាលាឃុំ សង្កាត់មួយ(១)ច្បាប់
- ផ្ញើជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌ មួយ(១)ច្បាប់
- ផ្ញើជូន គឃ/សប នៅក្នុងឃុំ សង្កាត់របស់ខ្លួនបី(៣)ច្បាប់ ជាបន្ទាន់ ។

▪ **សាលាក្រុង ស្រុក ខណ្ឌ**

គណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវប៉ូកសរុបរបាយការណ៍នេះក្នុងក្រុង ស្រុក ខណ្ឌរបស់ខ្លួនចំនួនពីរ(២)ច្បាប់ ចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រាក្រុង ស្រុក ខណ្ឌ រួចត្រូវ ៖

- ទុកជាឯកសារមួយ(១)ច្បាប់
- ផ្ញើជូនគណៈអភិបាលរាជធានី ខេត្ត មួយ(១)ច្បាប់ ។

- **សាលារាជធានី ខេត្ត**

គណៈអភិបាលរាជធានី ខេត្តត្រូវបូកសរុបរបាយការណ៍នេះក្នុងរាជធានី ខេត្តរបស់ខ្លួនចំនួនពីរ (២)ច្បាប់ ចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រារាជធានី ខេត្ត រួចត្រូវ ៖

- ទុកជាឯកសារចំនួនមួយ(១)ច្បាប់
- ផ្ញើជូនក្រសួងមហាផ្ទៃចំនួនមួយ(១)ច្បាប់ ។

- **គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប)**

គឃ/សប ត្រូវ ៖

- ទុកជាឯកសារចំនួនមួយ(១)ច្បាប់
- បិទផ្សាយភ្លាមចំនួនមួយ(១)ច្បាប់នៅ គឃ/សប
- ផ្ញើជូន គធ/ខប ជាបន្ទាន់ចំនួនមួយ(១)ច្បាប់ ។

- **គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ/ខប)**

គធ/ខប ត្រូវបូកសរុបរបាយការណ៍នេះក្នុងរាជធានី ខេត្តរបស់ខ្លួនចំនួនពីរ(២)ច្បាប់ ចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រា រួចត្រូវ ៖

- ទុកជាឯកសារចំនួនមួយ(១)ច្បាប់
- ផ្ញើជូន គ.ជ.ប ជាបន្ទាន់ចំនួនមួយ(១)ច្បាប់ ។

**ឆ- សុពលភាពប្រើប្រាស់ និងទណ្ឌកម្ម**

- លិខិតបញ្ជាក់នេះត្រូវដាក់ឱ្យប្រើប្រាស់ជំនួស ទ.១០១៨ ចាប់ពីក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ ។ ទ.១០១៨ ត្រូវទុកជាមោឃៈ ។
- លិខិតបញ្ជាក់ដែលថតចម្លង កែ កោស ឬលុប មិនអាចប្រើជាផ្លូវការបានឡើយ ។
- ជនណាក្លែងបន្លំ ឬចេញលិខិតបញ្ជាក់មិនត្រឹមត្រូវតាមនីតិវិធី នឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ៤. នីតិវិធីចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតចុងក្រោយ

### ក- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតថ្មី

អ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ គឺអ្នកពុំធ្លាប់បានចុះឈ្មោះបោះឆ្នោត អ្នកទើបគ្រប់អាយុ១៨ឆ្នាំ គិតមកដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ (កើតមុន ឬត្រឹមថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៥) អ្នកផ្លាស់ទីលំនៅថ្មីចូលមករស់នៅក្នុងឃុំ សង្កាត់ ទោះបីធ្លាប់បានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងក៏ដោយ អ្នកទាំងនោះត្រូវទៅជួបស្មៀន និងបង្ហាញឯកសារផ្លូវការណាមួយ ឬច្រើនដែលអាចបំពេញបាននូវលក្ខខណ្ឌទាំង៤សម្រាប់ ចុះឈ្មោះបោះឆ្នោត ។

**តើស្មៀនត្រូវអនុវត្តការងារយ៉ាងដូចម្តេច នៅពេលប្រជាពលរដ្ឋមកសុំចុះឈ្មោះបោះឆ្នោត ?**

ស្មៀនត្រូវ

- ធ្វើសម្ភាសន៍ដើម្បីឱ្យដឹងថា ពិតជាពុំធ្លាប់បានចុះឈ្មោះ ឬបានចុះឈ្មោះក្នុងការិយាល័យបោះឆ្នោតផ្សេង ឃុំ សង្កាត់ផ្សេង ឬបានចុះឈ្មោះហើយ តែសុំប្តូរការិយាល័យវិញ ។
- កំណត់លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតដែលនៅជិតល្មមនឹងលំនៅឋានរបស់គាត់ ។
- ផ្អែកលើឯកសារបញ្ជាក់អត្តសញ្ញាណដែលត្រូវប្រើនៅពេលបោះឆ្នោត បំពេញទម្រង់បែបបទចុះឈ្មោះបោះឆ្នោត (ទ. ១០២២) លើផ្នែកទាំងពីរ (២) ។
- ចុះលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់គាត់ (ប្រសិនបើមាន) ទៅក្នុង ទ.១០២២ លើផ្នែកទាំងពីរ(២) ។
- គូសសញ្ញាសម្គាល់ឯកសារដែលគាត់បានបង្ហាញឆ្លើយតបនឹងលក្ខខណ្ឌទាំង ៤ នៅលើ ទ. ១០២២ ។
- ចុះហត្ថលេខា កាលបរិច្ឆេទ បោះត្រាការិយាល័យចុះឈ្មោះនៅលើផ្នែកទាំងពីរ (២) នៃទម្រង់បែបបទចុះឈ្មោះបោះឆ្នោត (ទ. ១០២២) ។
- ហែកផ្នែកចុងសន្លឹកបង្កាន់ដៃជូនគាត់ និងជម្រាបគាត់ឱ្យចងចាំលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតផង ។
- សរសេរចូលភ្លាមក្នុងបញ្ជីបោះឆ្នោតបន្ថែម (ទ. ១០២៣) មួយ (១) ច្បាប់ ដោយស្រង់ទិន្នន័យចេញពីគល់សន្លឹក ទ. ១០២២ ។
- បើមានកំហុសក្នុងការបំពេញ ទ.១០២២ គូសខ្វែងចោលទាំង ២ផ្នែក ហើយសរសេរថា " លុបចោល " រួចបំពេញទម្រង់បែបបទចុះឈ្មោះបោះឆ្នោត (ទ. ១០២២) សាជាថ្មី ។

**ចំណាំ :**

- ស្មៀនគ្មានសិទ្ធិចុះឈ្មោះជូនអ្នកសុំចុះឈ្មោះដែលបានបង្ហាញខ្លួន តែខ្វះលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំង ៤ (អត្តសញ្ញាណ សញ្ជាតិ អាយុ និងទីលំនៅក្នុងឃុំ សង្កាត់) ។
- ស្មៀនគ្មានសិទ្ធិចុះឈ្មោះជូនអ្នកមិនមកបង្ហាញខ្លួនឡើយ ទោះបីមានឯកសារគ្រប់គ្រាន់ក៏ដោយ ។
- បើអ្នកសុំចុះឈ្មោះបានបង្ហាញឯកសារផ្លូវការណាមួយ ឬច្រើន ឃើញថាត្រឹមត្រូវតាមលក្ខខណ្ឌទាំង ៤ ហើយ ស្មៀនត្រូវចុះឈ្មោះជូនគាត់ មិនត្រូវដេញដោលសួរទៀតឡើយ ។

**ខ- ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ តែបានស្លាប់ បាត់បង់សិទ្ធិបោះឆ្នោត ផ្លាស់ទីលំនៅចេញពីឃុំ សង្កាត់ គ្មានទីលំនៅក្នុងឃុំ សង្កាត់ ឬជាជនអន្តោប្រវេសន៍ដែលស្មៀនត្រូវលុបឈ្មោះទាំងនោះចេញពីបញ្ជីបោះឆ្នោត ៖**

ស្មៀនត្រូវ

- មានឯកសារផ្លូវការជាភស្តុតាង(ឯកសារផ្លូវការពីមេឃុំ ចៅសង្កាត់ ឬនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់) ។
- ផ្អែកលើបញ្ជី (ទ.១០២៥) បំពេញទម្រង់បែបបទលុបឈ្មោះ (ទ.១០១៦) ចំនួនពីរ(២)ច្បាប់ ដោយបញ្ជាក់មូលហេតុដែលត្រូវលុប ។
- គូសបន្ទាត់លុបឈ្មោះពីបញ្ជីបោះឆ្នោតចុងក្រោយ ហើយចារទន្ទឹមនឹងឈ្មោះ " ស្លាប់ " ឬ " បាត់បង់សិទ្ធិ " ឬ " ផ្លាស់ចេញ " ឬ " គ្មានទីលំនៅក្នុងឃុំ សង្កាត់ " ។
- បំពេញ

ទ.១០១៦ = ២ ច្បាប់
- ១ ច្បាប់ ច្រកក្នុងស្រោមសំបុត្រជាមួយបញ្ជី (ទ.១០២៥) ខាងលើទុកសម្រាប់ដាក់ក្នុងកញ្ចប់ " ក "
- ១ ច្បាប់ ទុកជាឯកសារស្មៀន

**គ- ករណីអ្នកសុំប្តូរការិយាល័យបោះឆ្នោតពីឆ្ងាយមកជិតផ្ទះក្នុងឃុំ សង្កាត់**

ស្មៀនត្រូវ

- បំពេញទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃ (ទ.១០២២) ដោយអនុវត្តតាមចំណុច " ក " ។
- បំពេញទម្រង់បែបបទលុបឈ្មោះ ទ. ១០១៧ ចំនួន ២ ច្បាប់ និងឱ្យសាមីខ្លួនផ្តិតមេដៃ ។
  - ទ.១០១៧ = ២ ច្បាប់
    - ១ ច្បាប់ ច្រកក្នុងស្រោមសំបុត្រទុកសម្រាប់ដាក់ក្នុងកញ្ចប់ " ក "
    - ១ ច្បាប់ ទុកជាឯកសារស្មៀន
- គូសបន្ទាត់លុបឈ្មោះពីបញ្ជីបោះឆ្នោតចុងក្រោយ ចាប់ពីលេខរៀងដល់ចុងទិន្នន័យ រួចចារទន្ទឹមនឹងឈ្មោះនោះថា " ប្តូរការិយាល័យ " ។

**ឃ- ករណីអ្នកសុំចុះឈ្មោះដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់ផ្សេង ( អ្នកផ្លាស់ទីលំនៅចូល )**

ស្មៀនត្រូវ

- បំពេញទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃ (ទ. ១០២២) ដោយអនុវត្តតាមចំណុច " ក " ។
- ឱ្យគាត់បង្ហាញឯកសារភស្តុតាងបញ្ជាក់ថា គាត់បានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ឆ្នាំ២០១១ នៅឃុំ សង្កាត់ផ្សេង ។
- ចំពោះករណីអ្នកផ្លាស់ទីលំនៅចូល និងករណីឈ្មោះស្ទួន ប្រសិនបើគាត់ពុំមានឯកសារបញ្ជាក់ ឬពុំបានចាំលេខបង្កាន់ដៃ និងលេខការិយាល័យបោះឆ្នោត គ្រាន់តែបំពេញទិន្នន័យក្នុងចំណុច១នៃ ទ.១០១៧ ព្រមទាំងបំពេញឈ្មោះ ឬលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ដែលសាមីខ្លួនសុំលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ។
- បំពេញ ទ. ១០១៧ ចំនួន ២ ច្បាប់ និងឱ្យសាមីខ្លួនផ្តិតមេដៃ ។
  - ទ.១០១៧ = ២ច្បាប់
    - ១ច្បាប់ ច្រកក្នុងស្រោមសំបុត្រទុកសម្រាប់ដាក់ក្នុងកញ្ចប់ " ខ " ទី១
    - ១ច្បាប់ ទុកជាឯកសារស្មៀន

**ចំណាំ :**

☛ ករណីក្នុងចំណុច " **ឃ** " ការលុបឈ្មោះត្រូវធ្វើដោយមជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប ។

**ង- ករណីអ្នកបោះឆ្នោតមានឈ្មោះស្ទួនក្នុងការិយាល័យបោះឆ្នោតតែមួយ ឬផ្សេងក្នុងឃុំ សង្កាត់តែមួយ**

ស្មៀនត្រូវ

- ពិនិត្យឈ្មោះស្ទួនក្នុងបញ្ជីឈ្មោះស្ទួនក្នុងឃុំ សង្កាត់(ទ.១០២៦) ដែលផ្ញើឱ្យដោយ គ.ជ.ប ឱ្យប្រាកដថា ជាស្ទួនមែន ។
- ជួបសួរបញ្ជាក់សាមីខ្លួនឱ្យបានច្បាស់លាស់ ក្នុងករណីសង្ស័យជាមនុស្សផ្សេងគ្នា (ទិន្នន័យមិនដូចគ្នាទាំងស្រុង) ។
- ករណីឈ្មោះស្ទួនប្រាកដមែន រក្សាទុកឈ្មោះដែលបានចុះកាលបរិច្ឆេទចុងក្រោយ និងលុបឈ្មោះដែលបានចុះពីមុន ។
- បូកសរុបចំនួនឈ្មោះស្ទួនដែលត្រូវលុប និងចំនួនឈ្មោះដែលត្រូវរក្សាទុក ។
- ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាការិយាល័យ រួចដាក់ជូន កបឃ/ស ពិនិត្យសម្រេច ។
- ថតចម្លងបញ្ជីឈ្មោះស្ទួនដែលសម្រេចដោយ កបឃ/ស បន្ថែមចំនួនមួយ (១)ច្បាប់ ៖
  - បញ្ជីឈ្មោះស្ទួនក្នុងឃុំ សង្កាត់នេះ (ទ.១០២៦)
    - ១ច្បាប់ដើម ដាក់ក្នុងស្រោមសំបុត្រសម្រាប់ដាក់ក្នុងកញ្ចប់ " ខ " ទី១
    - ១ច្បាប់ រក្សាទុកជាឯកសារស្មៀន
- យោង ទ.១០២៦ នេះ គូសបន្ទាត់លុបឈ្មោះស្ទួនលើសដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត ។
- ចារទន្ទឹមឈ្មោះដែលលុបនោះថា " ស្ទួន " ។

**ច- ករណីអ្នកពិនិត្យបញ្ជីឈ្មោះ សុំកែតម្រូវឈ្មោះ ឬ/និងទិន្នន័យដែលសរសេរមិនត្រឹមត្រូវ ខុសអក្ខរាវិរុទ្ធ**

**ស្មៀនត្រូវ**

- ប្រើប៊ិកខៀវគូសរង្វង់មូលជុំវិញកន្លែងដែលសរសេរខុសនោះ ។
- សរសេរកែតម្រូវនៅក្បែររង្វង់មូល ដោយផ្អែកតាមឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការដែលគាត់បានបង្ហាញ ជាពិសេសតាមអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។
- បំពេញបង្កាន់ដៃទទួលកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត (ទ.១០២៨) ចុះលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់គាត់(ប្រសិនបើមាន) នៅលើផ្នែកទាំងពីរ(២) និង ឱ្យអ្នកសុំកែតម្រូវផ្តិតមេដៃនៅគល់បញ្ជី និងចុងសន្លឹកបង្កាន់ដៃ រួចហែកចុងសន្លឹកបង្កាន់ដៃជូនគាត់ ។

**ចំណាំ :** មុននឹងបង្កើតបញ្ជីបោះឆ្នោតដំបូង ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំសម្រេចលើករណីពាក់ព័ន្ធនឹងឈ្មោះដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត ដោយផ្អែកលើឯកសារភស្តុតាង។

## ៥. ការបដិសេធការសុំចុះឈ្មោះ

### ក- មូលហេតុនៃការបដិសេធ

- ខ្វះលក្ខខណ្ឌណាមួយ ឬច្រើនក្នុងចំណោមលក្ខខណ្ឌទាំង ៤ ។
- ជនដែលមកសុំចុះឈ្មោះក្រោយពេលកំណត់ ។
- ជនដែលត្រូវបានដកហូតសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្នដែលមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច។
- ជនវិកលចរិត ឬជនស្ថិតក្រោមអាណាព្យាបាលដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច។
- ជនស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ។

### ខ- នីតិវិធីនៃការបដិសេធ

ចំពោះអ្នកសុំចុះឈ្មោះដែលខ្វះលក្ខខណ្ឌ ហើយមកសុំចុះឈ្មោះក្នុងរយៈពេលកំណត់ ស្មៀនត្រូវ ៖

- ណែនាំអ្នកសុំចុះឈ្មោះឱ្យរកឯកសារដើម្បីបំពេញលក្ខខណ្ឌឱ្យអស់លទ្ធភាព ។
- ក្នុងករណីនៅតែខ្វះលក្ខខណ្ឌត្រូវសុំយោបល់សម្រេចពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការ។
  - បើសមាជិក ១ នាក់ → យកយោបល់សមាជិកនោះ
  - បើសមាជិក ២ នាក់ → យកយោបល់ភាគច្រើនក្នុងចំណោមសមាជិក ២ នាក់ និងស្មៀន ។
- **ពេលសម្រេចបដិសេធ**
  - បំពេញ ទ. ១០០៩ ចំនួន ៣ ច្បាប់ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាការិយាល័យចុះឈ្មោះ

ទ.១០០៩ = ៣ ច្បាប់
- ១ ច្បាប់ ជូនអ្នកសុំចុះឈ្មោះ
- ១ ច្បាប់ ជូន គ.ជ.ប
- ១ ច្បាប់ ទុកជាឯកសារស្មៀន

- ជូន ទ. ១២០២ ចំនួន ៣ ច្បាប់ ( ប្រសិនបើគាត់សុំ )
- ជម្រាបគាត់ឱ្យបំពេញពាក្យប្តឹង (ទ.១២០២) ទាំង ៣ច្បាប់ រួចយកទៅដាក់នៅ កបឃ/ស ក្នុងរយៈពេលបី(៣)ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលសេចក្តីសម្រេចបដិសេធ(ទ.១០០៩) ។

## ៦. ការប្តឹងតវ៉ា និងការដោះស្រាយបណ្តឹង

### ក- ការដាក់បណ្តឹងតវ៉ានៅ កបឃ/ស និងការប្រជុំសម្រេចជាសាធារណៈ

- អ្នកប្តឹងបំពេញ ទ. ១២០២ ទាំង ៣ ច្បាប់ ។ ពាក្យបណ្តឹងត្រូវដាក់នៅ កបឃ/ស តាមការកំណត់ ។
- ប្រធាន ឬសមាជិក កបឃ/ស ដែលបានទទួលសិទ្ធិត្រូវ ៖
  - បើអ្នកប្តឹងយកបណ្តឹង (ទ.១២០២) មកដាក់ក្រោយពេលកំណត់ ត្រូវចុះកាលបរិច្ឆេទ ពេលវេលានៃការទទួល → ចាត់ទុកថាមិនបានប្តឹងតវ៉ា ហើយត្រូវចារលើបណ្តឹង(ទ.១២០២) ថា "បណ្តឹងបានទទួលក្រោយពេលកំណត់ នៅថ្ងៃទី..........ខែ............ ឆ្នាំ២០១២ " ចុះហត្ថលេខា បោះត្រា ។

ទ.១២០២ = ៣ច្បាប់
- ១ ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ ច្បាប់ ច្រកក្នុងស្រោមសំបុត្រទុកត្រៀមដាក់ក្នុងកញ្ចប់ " ខ " ទី១ ផ្ញើជូន គ.ជ.ប
- ១ ច្បាប់ ទុកជាឯកសារ

  - បើអ្នកប្តឹងយកបណ្តឹង(ទ.១២០២)មកដាក់ក្នុងរយៈពេលកំណត់ ត្រូវចុះកាលបរិច្ឆេទ ពេលវេលានៃការទទួល លើពាក្យប្តឹង(ទ.១២០២)ទាំង ៣ច្បាប់ និងពេលវេលា កាលបរិច្ឆេទ ទីកន្លែងដែលត្រូវបើកការប្រជុំសម្រេច ជាសាធារណៈ ចុះហត្ថលេខា បោះត្រា ។

ទ.១២០២ = ៣ច្បាប់
- ១ ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់របស់ខ្លួន
- ១ ច្បាប់ ទុកប្រើប្រាស់ក្នុងការប្រជុំសម្រេច

- **ការប្រជុំសម្រេច**
  - មានរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យប្តឹង ។
  - មានលក្ខណៈដូចគ្នានឹងការប្រជុំសាមញ្ញរបស់ កបឃ/ស (យកសំឡេងភាគច្រើនដាច់ខាត) ។
  - ដោះស្រាយតាមលក្ខខណ្ឌតម្រូវសម្រាប់ការចុះឈ្មោះ ។
  - ពិចារណាពីមូលហេតុនៃការបដិសេធលើ ទ.១០០៩ របស់ស្មៀនឃុំ សង្កាត់ ។

- **ករណីសម្រេចបដិសេធបណ្តឹង**
  - ស្រង់សេចក្តីសម្រេចបដិសេធពីកំណត់ហេតុប្រជុំសម្រេចដាក់ក្នុង ទ.១២០៣ ចំនួន ៣ ច្បាប់ ដោយបញ្ជាក់មូលហេតុ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់ ។

ទ. ១២០៣ = ៣ ច្បាប់
- ១ ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ ច្បាប់ ទុកជាឯកសារ

- ជូនអ្នកប្តឹង ទ.១២០២ ចំនួន ៣ ច្បាប់ ( ប្រសិនបើគាត់ស្នើសុំ) ជម្រាបគាត់ឱ្យបំពេញពាក្យប្តឹង (ទ.១២០២) រួចយកទៅដាក់នៅ គ.ជ.ប (នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម) យ៉ាងយូរ ៥ ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចបដិសេធ (ទ.១២០៣) ។

- **ករណីសម្រេចយល់ព្រម**

  - ស្រង់សេចក្តីសម្រេចយល់ព្រមពីកំណត់ហេតុប្រជុំសម្រេចដាក់ក្នុង ទ.១២០៣ ចំនួន ៣ច្បាប់ ចុះហត្ថលេខា កាលបរិច្ឆេទ បោះត្រាឃុំ សង្កាត់ ។

ទ. ១២០៣ = ៣ ច្បាប់
- ១ ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ ច្បាប់ ទុកជាឯកសារ

  - ស្មៀនណាត់អ្នកសុំចុះឈ្មោះ ដើម្បីអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោត ។

**ខ- ការដាក់បណ្តឹងតវ៉ានៅ គ.ជ.ប និងការបើកសវនាការជាសាធារណៈ**

- រយៈពេលប្តឹង ៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលសម្រង់សេចក្តីសម្រេចបដិសេធរបស់ កបឃ/ស ។
- ជូនដំណឹងពីពេលវេលា កាលបរិច្ឆេទ ទីកន្លែងបើកសវនាការយ៉ាងតិចមួយ (១) ថ្ងៃ មុនថ្ងៃបើកសវនាការ ។
- បើកសវនាការសម្រេចក្នុងអំឡុងពេលយ៉ាងយូរ ៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបណ្តឹង (ទ.១២០២) ។

- **ករណីបដិសេធបណ្តឹងតវ៉ា**

  - ស្រង់សេចក្តីសម្រេចបដិសេធពីកំណត់ហេតុសវនាការដាក់ក្នុង ទ.១២០៣ ចំនួន ៣ ច្បាប់ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ។

ទ. ១២០៣ = ៣ ច្បាប់
- ១ ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ ច្បាប់ ជូនក្រុមប្រឹក្សាធម្មនុញ្ញ
- ១ ច្បាប់ ទុកជាឯកសារ

  - ជម្រាបគាត់ថា គាត់អាចដាក់ពាក្យប្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញយ៉ាងយូរ ៥ថ្ងៃ បន្ទាប់ពីថ្ងៃបាន ទទួលសម្រង់សេចក្តីសម្រេចបដិសេធ( ទ. ១២០៣) ។

- **ករណីយល់ព្រមតាមបណ្តឹងតវ៉ា**

  - ស្រង់សេចក្តីសម្រេចយល់ព្រមពីកំណត់ហេតុសវនាការដាក់ក្នុង ទ.១២០៣ ចំនួន ៣ច្បាប់ ចុះហត្ថលេខា កាលបរិច្ឆេទ បោះត្រា ។

ទ.១២០៣ = ៣ ច្បាប់
- ១ ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន កបឃ/ស
- ១ ច្បាប់ ទុកជាឯកសារ

  - ស្មៀនណាត់អ្នកសុំចុះឈ្មោះ ដើម្បីអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោត ។
  - ស្មៀនផ្ញើមក គ.ជ.ប ( មជ្ឈមណ្ឌលកុំព្យូទ័រ ) នូវគល់សន្លឹក ទ. ១០២២ ពាក់ព័ន្ធ ។

**គ- ការដាក់បណ្តឹងតវ៉ានៅក្រុមប្រឹក្សាធម្មនុញ្ញ និងការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ**

- រយៈពេលប្តឹង ៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចបដិសេធរបស់ គ.ជ.ប ។
- ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចក្នុងរយៈពេល ១០ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យប្តឹង ។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចចុងក្រោយ បិទផ្លូវតវ៉ា ។
- **ករណីសម្រេចបដិសេធ**
  - ចេញសេចក្តីសម្រេចបដិសេធ ក្នុងនោះ

    សេចក្តីសម្រេចបដិសេធ = ២ ច្បាប់ { - ១ ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
    - ១ ច្បាប់ ជូន គ.ជ.ប

- **ករណីសម្រេចយល់ព្រម**
  - ចេញសេចក្តីសម្រេចយល់ព្រម ក្នុងនោះ

    សេចក្តីសម្រេចយល់ព្រម = ២ ច្បាប់ { - ១ ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
    - ១ ច្បាប់ ជូន គ.ជ.ប

  - គ.ជ.ប ជូនដំណឹងព្រមទាំងផ្ញើច្បាប់ដើមនៃសេចក្តីសម្រេចនេះទៅ កបឃ/ស ។
  - ស្មៀនណាត់អ្នកសុំចុះឈ្មោះជាមុន រួចអនុវត្តការចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតបន្ថែម ។
  - ស្មៀនត្រូវផ្ញើមក គ.ជ.ប ( មជ្ឈមណ្ឌលកុំព្យូទ័រ ) នូវគល់សន្លឹក ទ. ១០២២ ពាក់ព័ន្ធ ។
  - ស្មៀនរក្សាទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាឯកសារ ។

# គំនូសបំព្រួញ អំពីពេលវេលា
# នៃការប្ដឹងតវ៉ា និងការដោះស្រាយបណ្ដឹង
# ក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត



## V. បញ្ជីបោះឆ្នោតដំបូង

១. ការពិនិត្យផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពរួច បញ្ជីបោះឆ្នោតបន្ថែម បញ្ជីបោះឆ្នោតនៃការិយាល័យបង្កើតថ្មី ( ការផ្ទៀងផ្ទាត់ត្រូវធ្វើបន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត )

**ក- ការផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពរួច ដោយផ្អែកលើ ទ. ១០១៦ និង ទ. ១០១៧ និងចំនួនឈ្មោះលុបក្នុង ទ.១០២៦ ស្រង់ដោយ គ.ជ.ប**

**ស្មៀនត្រូវផ្ទៀងផ្ទាត់ឱ្យប្រាកដថា**

- តើចំនួន ទ.១០១៦ បូកចំនួន ទ.១០១៧ និងចំនួនឈ្មោះលុបក្នុង ទ.១០២៦ ស្រង់ដោយ គ.ជ.ប ស្មើគ្នានឹងចំនួនឈ្មោះដែលបានលុបក្នុងបញ្ជីបោះឆ្នោតចុងក្រោយដែរឬទេ? (ដោយមិនគិតបញ្ចូលចំនួន ទ.១០១៧ ដែលត្រូវលុបឈ្មោះក្រៅឃុំ សង្កាត់ ដោយមជ្ឈមណ្ឌលកុំព្យូទ័រនៃ គ.ជ.ប ) ។
- តើបានលុបឈ្មោះហើយឬនៅ ? បានបោះត្រាការិយាល័យគ្រប់សន្លឹក ហើយឬនៅ ?
- តើបានកែតម្រូវឈ្មោះ ឬ/និងទិន្នន័យដោយប៊ិកខៀវរួចរាល់អស់ហើយ ឬនៅ ?
- តើសន្លឹកចុងក្រោយនៃបញ្ជីបោះឆ្នោតចុងក្រោយ បានចារបំពេញតួលេខ ចំនួនសរុបនៃឈ្មោះអ្នកបោះឆ្នោតដែលត្រូវលុប និងដែលត្រូវរក្សាទុក រួចហើយ ឬនៅ ? បានចុះហត្ថលេខា បោះត្រា ចុះកាលបរិច្ឆេទ រួចហើយ ឬនៅ ?

**រូបមន្ត** ⇨ **ចំនួនឈ្មោះលុបក្នុងបញ្ជី = ចំនួន ទ.១០១៦ + ចំនួន ទ.១០១៧ + ចំនួនឈ្មោះលុបក្នុង ទ.១០២៦ ស្រង់ដោយ គ.ជ.ប (ដោយមិនគិតបញ្ចូលចំនួន ទ.១០១៧ ដែលត្រូវលុបឈ្មោះក្រៅឃុំ សង្កាត់នៅមជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប)**

**ខ- ការផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតបន្ថែម**

**ស្មៀនត្រូវផ្ទៀងផ្ទាត់ឱ្យប្រាកដថា**

- តើចំនួនគល់សន្លឹកនៃទម្រង់បែបបទចុះឈ្មោះ ស៊ីគ្នានឹងចំនួនឈ្មោះដែលបានចុះក្នុងបញ្ជីបោះឆ្នោតបន្ថែមដែរឬទេ ? ( ដោយមិនគិតបញ្ចូល ទ.១០២២ ដែលសរសេរខុសគូសលុបចោល) ។
- តើបានបោះត្រាលើសន្លឹកនីមួយៗ ហើយឬនៅ ?
- តើសន្លឹកចុងក្រោយនៃបញ្ជីបោះឆ្នោតបន្ថែម បានចារបំពេញរួចហើយ ឬនៅ ? ចុះហត្ថលេខា បោះត្រា ចុះកាលបរិច្ឆេទ ហើយឬនៅ ?
- តើបានចុះលេខទូរស័ព្ទរបស់ខ្លួន ហើយឬនៅ ? ( ប្រសិនបើមាន)

**រូបមន្ត** ⇨ **ចំនួនឈ្មោះដែលមានក្នុងបញ្ជីបោះឆ្នោតបន្ថែម** = **ចំនួនគល់សន្លឹក ទ.១០២២ ( ដោយមិនគិតបញ្ចូលសន្លឹកខូច )**

គ- ការផ្ទៀងផ្ទាត់លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះតាមការិយាល័យចាស់

រូបមន្ត ⇨ ចំនួនឈ្មោះដែលបានរក្សាទុកក្នុងបញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពរួច = ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ - ចំនួនឈ្មោះដែលបានលុបចេញពីបញ្ជីបោះឆ្នោតចុងក្រោយ

ឃ- ការផ្ទៀងផ្ទាត់លទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៃការិយាល័យបង្កើតថ្មី

រូបមន្ត ⇨ ចំនួនឈ្មោះនៃអ្នកចុះឈ្មោះបោះឆ្នោតនៃការិយាល័យបង្កើតថ្មី = ចំនួនគល់សន្លឹក ទ.១០២២ ( ដោយមិនគិតបញ្ចូលសន្លឹកខូច )

២. ការរៀបចំបញ្ជីបោះឆ្នោតដំបូង

ក- ការផ្គុំបញ្ចូលគ្នារវាងបញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពរួច ជាមួយនឹងបញ្ជីបោះឆ្នោតបន្ថែមនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ( ធ្វើភ្លាមបន្ទាប់ពីការផ្ទៀងផ្ទាត់ )

ស្មៀនត្រូវយកបញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាព និងបានផ្ទៀងផ្ទាត់រួចនៃការិយាល័យបោះឆ្នោតនីមួយៗ មកផ្គុំបញ្ចូលគ្នាជាមួយនឹងបញ្ជីបោះឆ្នោតបន្ថែមនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធដែលផ្ទៀងផ្ទាត់រួច កើតបានជាបញ្ជីបោះឆ្នោតដំបូង ។

បញ្ជីបោះឆ្នោតដំបូង = បញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាព និងផ្ទៀងផ្ទាត់រួច + បញ្ជីបោះឆ្នោតបន្ថែមដែលបានផ្ទៀងផ្ទាត់រួច

ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង = ចំនួនឈ្មោះរក្សាទុកក្នុងបញ្ជីបោះឆ្នោតចុងក្រោយ + ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោតបន្ថែម

ខ- ការរៀបចំបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបង្កើតថ្មី

រូបមន្ត ⇨

បញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតបង្កើតថ្មី = បញ្ជីបោះឆ្នោតបន្ថែមនៃការិយាល័យបោះឆ្នោតបង្កើតថ្មី

ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតបង្កើតថ្មី = ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោតបន្ថែមនៃការិយាល័យបោះឆ្នោតបង្កើតថ្មី

៣. របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត

( ធ្វើបន្ទាប់ពីការផ្គុំបញ្ចូលគ្នារវាងបញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពរួច ជាមួយនឹងបញ្ជីបោះឆ្នោតបន្ថែម )

- ស្មៀនឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន ។

ក- ការបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ៤ច្បាប់

( មើល និងបំពេញតាម ទ.១០១១ ដែលមានស្រាប់ )

- បំពេញលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត
  - ▪ បំពេញលេខកូដរាជធានី ខេត្ត និងលេខកូដឃុំ សង្កាត់

**ខ- ការប្រើប្រាស់ ទ.១០១១**

ទ.១០១១ = ៤ ច្បាប់
- -១ច្បាប់ ច្រកក្នុងស្រោមសំបុត្រ ទុកដាក់ក្នុងកញ្ចប់ " ក"
- -២ច្បាប់ ដាក់កិបភ្ជាប់ផ្នែកខាងក្រៅកញ្ចប់ " ក"
- -១ច្បាប់ ទុកជាឯកសារ

**ចំណាំ :**

- ការិយាល័យដែលគ្មានការបដិសេធការសុំចុះឈ្មោះត្រូវធ្វើរបាយការណ៍លទ្ធផល(ទ.១០១១)បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងនៅមុនពេលវេចខ្ចប់កញ្ចប់" ក" ។
- ការិយាល័យដែលមានការបដិសេធការសុំចុះឈ្មោះ ប៉ុន្តែគ្មានបណ្តឹងតវ៉ាដាក់នៅ កបឃ/ស ក្នុងរយៈពេលបី(៣)ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ត្រូវធ្វើរបាយការណ៍លទ្ធផល(ទ.១០១១) នៅថ្ងៃទី៤ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។
- ការិយាល័យណាមានបណ្តឹងតវ៉ាដាក់នៅ កបឃ/ស ត្រូវធ្វើរបាយការណ៍លទ្ធផល (ទ.១០១១) បន្ទាប់ពី កបឃ/ស ដោះស្រាយបណ្តឹងចប់ និងនៅមុនពេលវេចខ្ចប់កញ្ចប់ " ក " គឺយ៉ាងយូរនៅថ្ងៃទី ៧ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

**៤. ការថតចម្លងបញ្ជីបោះឆ្នោតចុងក្រោយដែលធ្វើបច្ចុប្បន្នភាពរួច បញ្ជីបោះឆ្នោតបន្ថែម និងបញ្ជីបោះឆ្នោតនៃការិយាល័យបង្កើតថ្មី**(ធ្វើភ្លាមបន្ទាប់ពីបំពេញ ទ.១០១១ រួច)

**ក- ករណីស្មៀនឃុំ សង្កាត់មានលទ្ធភាពរកទីកន្លែងថតចម្លងបាន**

**ស្មៀនត្រូវថតចម្លង** ⇒
- បញ្ជីបោះឆ្នោតចុងក្រោយដែលធ្វើបច្ចុប្បន្នភាពរួច និងបញ្ជីបោះឆ្នោតបន្ថែម។
- -បញ្ជីបោះឆ្នោតនៃការិយាល័យបង្កើតថ្មី។

⇒ មួយមុខៗឱ្យបានបី(៣)ច្បាប់ គម្រប់ជាបួន(៤)ច្បាប់ គិតទាំងច្បាប់ដើម

**ខ- ករណីស្មៀនឃុំ សង្កាត់ពុំមានលទ្ធភាពរកទីកន្លែងថតចម្លងបាន**

**ស្មៀនត្រូវបញ្ជូន** ⇒
- បញ្ជីបោះឆ្នោតចុងក្រោយដែលធ្វើបច្ចុប្បន្នភាពរួច និងបញ្ជីបោះឆ្នោតបន្ថែម ។
- បញ្ជីបោះឆ្នោតនៃការិយាល័យបង្កើតថ្មី។

⇒ ទៅ លធ/ខប

**លធ/ខប ត្រូវ** ⇒
- ថតចម្លង១មុខៗឱ្យបាន ៣ច្បាប់ គម្រប់ជា ៤ច្បាប់ គិតទាំងច្បាប់ដើម ។
- ប្រគល់ជូនស្មៀនវិញទាំង ៤ច្បាប់ គ្រប់មុខទាំងអស់ ជាបន្ទាន់។

## ៥. ការវេចខ្ចប់កញ្ចប់ " ក "

- ស្មៀនឃុំ សង្កាត់ត្រូវរៀបចំឯកសារផ្សេងៗនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធដាក់ចូលក្នុងកញ្ចប់ " ក " នីមួយៗនៃឃុំ សង្កាត់របស់ខ្លួន ។
- ការវេចខ្ចប់កញ្ចប់ " ក " ទាំងអស់នេះ ត្រូវធ្វើភ្លាមបន្ទាប់ពីការថតចម្លងបញ្ជីបោះឆ្នោតចុងក្រោយដែលធ្វើបច្ចុប្បន្នភាពរួច បញ្ជីបោះឆ្នោតបន្ថែម និងបញ្ជីបោះឆ្នោតនៃការិយាល័យបង្កើតថ្មី ។
- ការរៀបចំដាក់ឯកសារផ្សេងៗនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធចូលក្នុងកញ្ចប់ " ក "នីមួយៗ ៖

**សម្រាប់ការិយាល័យបោះឆ្នោតចាស់**

**កញ្ចប់ " ក "**

**(ដាក់សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត)**

☐☐ ☐☐☐ ☐☐☐☐

រាជធានី ខេត្ត ឃុំ សង្កាត់ ការិយាល័យបោះឆ្នោត

១- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលធ្វើបច្ចុប្បន្នភាពរួច និងបញ្ជីបោះឆ្នោតបន្ថែមនៃការិយាល័យពាក់ព័ន្ធ ចំនួន ១ ច្បាប់ ។

២- ស្រោមសំបុត្រដាក់រួមបញ្ចូលគ្នា ៖

+ ទ. ១០១៦ នៃការិយាល័យពាក់ព័ន្ធ
+ ទ.១០១៧ នៃការិយាល័យពាក់ព័ន្ធ ( សម្រាប់តែករណីប្តូរការិយាល័យ និងករណីឈ្មោះស្ទួនក្នុងឃុំ សង្កាត់ តែមួយ) ។
+ ទ.១០២៥ នៃការិយាល័យពាក់ព័ន្ធ។
+ រាល់ឯកសារភស្តុតាងពាក់ព័ន្ធនឹង ទ.១០១៦ និង ទ.១០១៧។

៣- ស្រោមសំបុត្រដាក់សម្រង់សេចក្តីសម្រេចយល់ព្រមតាមបណ្តឹងតវ៉ា (ទ.១២០៣) ។

៤- ស្រោមសំបុត្រដាក់របាយការណ៍លទ្ធផល (ទ.១០១១) នៃការិយាល័យ ចំនួន ១ ច្បាប់ ។

ទ. ១០១១ ចំនួន ២ច្បាប់
កិបភ្ជាប់ពីខាងក្រៅកញ្ចប់" ក"

**សម្រាប់ការិយាល័យបោះឆ្នោតបង្កើតថ្មី**

**កញ្ចប់ " ក "**

**(ដាក់សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត)**

☐☐ ☐☐☐ ☐☐☐☐

រាជធានី ខេត្ត ឃុំ សង្កាត់ ការិយាល័យបោះឆ្នោត

១- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតបង្កើតថ្មី ចំនួន ១ច្បាប់ ។

២- ស្រោមសំបុត្រដាក់សម្រង់សេចក្តីសម្រេចយល់ព្រមតាមបណ្តឹងតវ៉ា (ទ.១២០៣) ។

៣- ស្រោមសំបុត្រដាក់របាយការណ៍លទ្ធផល (ទ.១០១១) នៃការិយាល័យ ចំនួន ១ ច្បាប់ ។

ទ. ១០១១ ចំនួន ២ច្បាប់
កិបភ្ជាប់ពីខាងក្រៅកញ្ចប់" ក"

**ចំណាំ :**

- ធ្វើចំពោះមុខសមាជិក កបឃ/ស តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ ។
- ផ្ទៀងផ្ទាត់សម្ភារៈឯកសារក្នុងកញ្ចប់ " ក " ឡើងវិញឱ្យប្រាកដថាត្រឹមត្រូវហើយ ។
- បិទភ្ជិតកញ្ចប់"ក" ចំពោះមុខសមាជិក កបឃ/ស តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ ។
- សរសេរលើកញ្ចប់" ក " ដោយប៊ិកហ្វឺតលុបមិនជ្រះ នូវលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ ការិយាល័យបោះឆ្នោតឱ្យបានត្រឹមត្រូវ ។
- ថែរក្សាទុកកញ្ចប់ " ក" ឱ្យមានសុវត្ថិភាពមុនពេលវេចខ្ចប់កញ្ចប់ " ក " នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ចូលក្នុងកញ្ចប់ " ខ" ។

## ៦. របាយការណ៍បូកសរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់

### ក- ការធ្វើរបាយការណ៍បូកសរុបលទ្ធផល ( ទ.១០១២ )

- ស្មៀនឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។
- ធ្វើភ្លាមបន្ទាប់ពីវេចខ្ចប់កញ្ចប់ " ក " រួចរាល់គ្រប់ការិយាល័យទាំងអស់ក្នុងឃុំ សង្កាត់ និងដោយ ៖
  - ផ្អែកលើ ទ.១០១១ នៃការិយាល័យទាំងអស់ក្នុងឃុំ សង្កាត់
  - បូកសរុបបញ្ចូលគ្នាតាមខ្ទង់នីមួយៗរបស់ចំណុចទី ២ នៃ ទ.១០១១ ទាំងអស់
  - ឃើញថាត្រឹមត្រូវហើយ ស្រង់បញ្ចូលគ្នាតាមខ្ទង់ដែលមានក្នុងចំណុចតូចទី ៣ នៃរបាយការណ៍សរុបលទ្ធផលក្នុងឃុំ សង្កាត់ ( ទ.១០១២ ) ។

**ចំណាំ :**

☛ ផ្ទៀងផ្ទាត់ឡើងវិញ និងធ្វើប្រមាណវិធីឱ្យបានត្រឹមត្រូវ មុននឹងស្រង់ចូលក្នុង ទ.១០១២ ។

### ខ- ការប្រើប្រាស់របាយការណ៍បូកសរុបលទ្ធផលក្នុងឃុំ សង្កាត់ (ទ.១០១២)

ទ. ១០១២ = ៣ ច្បាប់
- ២ ច្បាប់ ច្រកក្នុងស្រោមសំបុត្រ ទុកដាក់ក្នុងកញ្ចប់ " ខ " ទី ១
- ១ ច្បាប់ ទុកជាឯកសារឃុំ សង្កាត់

## ៧. របាយការណ៍ស្តីពីតុល្យភាពនៃការទទួលនិងការប្រើប្រាស់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០២១)

ក- ធ្វើភ្លាមបន្ទាប់ពីធ្វើរបាយការណ៍បូកសរុបលទ្ធផល ( ទ.១០១២ ) ។

ខ- ដកស្រង់ពី ទ.១០១២ មកចុះក្នុង ទ.១០២១ ។

គ- ការប្រើប្រាស់របាយការណ៍តុល្យភាព ( ទ.១០២១ ) ៖

ទ.១០២១ = ៣ ច្បាប់
- ១ ច្បាប់ ច្រកក្នុងស្រោមសំបុត្រទុកដាក់ចូលក្នុងកញ្ចប់ដាក់ ទ.១០២២
- ១ ច្បាប់ កិបភ្ជាប់ខាងក្រៅកញ្ចប់ដាក់ ទ. ១០២២ ជូន លធ/ឧប
- ១ ច្បាប់ ទុកជាឯកសារឃុំ សង្កាត់

## ៨. ការវេចខ្ចប់កញ្ចប់ដាក់សៀវភៅទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃ (ទ.១០២២) ដែលបានប្រើហើយ



**ចំណាំ ៖**

- រាល់ទម្រង់បែបបទចុះឈ្មោះបោះឆ្នោត /បង្កាន់ដៃដែលនៅសល់ទាំងអស់ ស្មៀនឃុំ សង្កាត់ ត្រូវធ្វើរបាយការណ៍ជូន លធ/ខប និងរក្សាទុកឱ្យបានហ្មត់ចត់ក្នុងកេសស័ង្កសី សម្រាប់ប្រើប្រាស់នៅពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនាឆ្នាំបន្តបន្ទាប់ទៀត ។
- សៀវភៅ ទ.១០២២ ដែលនៅសល់ពីឆ្នាំមុនៗ ក៏នៅមានសុពលភាពក្នុងការប្រើប្រាស់សម្រាប់ឆ្នាំ២០១២ នេះ និងឆ្នាំបន្តបន្ទាប់ទៀត ។

## ៩. ការវេចខ្ចប់កញ្ចប់ " ខ " សម្រាប់បញ្ជូនទៅ លធ/ខប

- ស្មៀនឃុំ សង្កាត់ត្រូវវេចខ្ចប់កញ្ចប់ " ខ " នៃឃុំ សង្កាត់របស់ខ្លួន ។
- នៅមុនពេលចងភ្ជិតកញ្ចប់ " ខ " នីមួយៗ ស្មៀនឃុំ សង្កាត់ត្រូវបំពេញលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនកញ្ចប់ " ខ " (ទ. ១០១៣) ចំនួន ៤ ច្បាប់សម្រាប់កញ្ចប់ " ខ " នីមួយៗ ។

ទ.១០១៣ = ៤ ច្បាប់
- ២ ច្បាប់ ច្រកក្នុងស្រោមសំបុត្រទុកដាក់ក្នុងកញ្ចប់ " ខ " នីមួយៗ
- ១ ច្បាប់ ដាក់ចូលក្នុងហោប៉ៅក្រៅនៃកញ្ចប់ " ខ " នីមួយៗ
- ១ ច្បាប់ ស្មៀនរក្សាទុកសម្រាប់ប្រើប្រាស់ក្នុងការប្រគល់ ទទួលកញ្ចប់ " ខ " នីមួយៗ នៅ លធ/ខប

### ក- ការវេចខ្ចប់កញ្ចប់ " ខ " ទី១ រួមមាន ៖

- កញ្ចប់ដាក់សៀវភៅ ទ.១០២២ ដែលបានប្រើហើយ ។
- ស្រោមសំបុត្រដាក់របាយការណ៍សរុបលទ្ធផល ( ទ.១០១២ ) ចំនួន ២ ច្បាប់ ។
- ស្រោមសំបុត្រដាក់រាល់ ទ.១០១៧ (ករណីផ្លាស់ទីលំនៅចូល ឬឈ្មោះស្ទួនក្រៅឃុំ សង្កាត់) និងបញ្ជីឈ្មោះស្ទួនដែលត្រូវលុបឈ្មោះចេញ ។
- ស្រោមសំបុត្រដាក់បញ្ជីឈ្មោះស្ទួនក្នុងឃុំ សង្កាត់ ស្រង់ដោយ គ.ជ.ប ( ទ.១០២៦) ។
- ស្រោមសំបុត្រដាក់រាល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត ( ទ.១០០៩ ) ។
- ស្រោមសំបុត្រដាក់រាល់សម្រង់សេចក្តីសម្រេចបដិសេធរបស់ កបឃ/ស ( ទ.១២០៣) ។
- ស្រោមសំបុត្រដាក់រាល់បណ្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះដែលដាក់ក្រោយពេលកំណត់ ( ទ.១២០២) ។
- ស្រោមសំបុត្រដាក់រាល់គល់សន្លឹកបង្កាន់ដៃទទួលកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត ( ទ.១០២៨) ។
- របាយការណ៍ស្តីពីលទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ផ្ញើជូន លធ/ខប ចំនួន ១ច្បាប់
- ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនកញ្ចប់ "ខ" ( ទ.១០១៣ ) ចំនួន ២ ច្បាប់ ។

### ខ- ការវេចខ្ចប់កញ្ចប់ " ខ " ទី២ និងកញ្ចប់ " ខ " បន្តបន្ទាប់ រួមមាន ៖

- កញ្ចប់ " ក " តាមចំនួនដែលអាចដាក់បានក្នុងកញ្ចប់ " ខ " នីមួយៗ (រៀបតាមលេខកូដជាប់ៗគ្នា តាមលំដាប់លំដោយ ) ។
- ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនកញ្ចប់ " ខ " ( ទ. ១០១៣ ) ចំនួន ២ ច្បាប់ ។


កញ្ចប់ " ខ " ទី១
រាជធានី ខេត្ត
ឃុំ សង្កាត់
១- កញ្ចប់ដាក់សៀវភៅ ទ.១០២២ ដែលបានប្រើហើយ ។
២- ស្រោមសំបុត្រដាក់របាយការណ៍សរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុង ឃុំ សង្កាត់ ( ទ.១០១២ ) ចំនួន២ ច្បាប់ ។
៣- ស្រោមសំបុត្រដាក់ ទ.១០១៧ (ករណីផ្លាស់ទីលំនៅចូល ឬឈ្មោះស្ទួនក្រៅឃុំ សង្កាត់) និង បញ្ជីឈ្មោះស្ទួនដែលត្រូវលុបឈ្មោះចេញ ។
៤- ស្រោមសំបុត្រដាក់បញ្ជីឈ្មោះស្ទួនក្នុងឃុំ សង្កាត់ ស្រង់ដោយ គ.ជ.ប (ទ.១០២៦) ។
៥- ស្រោមសំបុត្រដាក់រាល់សម្រង់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះ (ទ.១០០៩) ។
៦- ស្រោមសំបុត្រដាក់រាល់សម្រង់សេចក្តីសម្រេចបដិសេធរបស់ កបឃ/ស (ទ.១២០៣ ) ។
៧- ស្រោមសំបុត្រដាក់រាល់បណ្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះដែលដាក់នៅក្រោយពេលកំណត់ (ទ.១២០២) ។
៨- ស្រោមសំបុត្រដាក់រាល់គល់សន្លឹកបង្កាន់ដៃទទួលកែតម្រូវឈ្មោះឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត (ទ.១០២៨) ។
៩- របាយការណ៍ស្តីពីលទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ។
១០- ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់ សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនកញ្ចប់ " ខ " ( ទ. ១០១៣ ) ចំនួន ២ ច្បាប់ ។
ទ.១០១៣
ចំនួន ១ ច្បាប់


កញ្ចប់ " ខ " ទី២
រាជធានី ខេត្ត
ឃុំ សង្កាត់
-ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់ សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត និង ការបញ្ជូនកញ្ចប់ " ខ " (ទ.១០១៣) ចំនួន ២ ច្បាប់ ។
ទ.១០១៣ ចំនួន ១ច្បាប់

**កំណត់សម្គាល់**

រាល់ការវេចខ្ចប់កញ្ចប់"ខ" ទី ១ កញ្ចប់ "ខ" ទី២ និងកញ្ចប់ "ខ" បន្តបន្ទាប់ ស្មៀនឃុំ សង្កាត់ត្រូវ ៖

- ផ្ទៀងផ្ទាត់ឡើងវិញ នូវរាល់សម្ភារៈដែលត្រូវដាក់ក្នុងកញ្ចប់ "ខ" នីមួយៗ ។
- ចងភ្ជិត រក្សាការពារសុវត្ថិភាព មុនពេល និងក្នុងពេលបញ្ជូន ។
- ប្រើប៊ិកហ្វឺតលុបមិនជ្រះ សរសេរលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ឱ្យបានត្រឹមត្រូវ ។
- ដាក់ ទ.១០១៣ មួយ(១)ច្បាប់ ក្នុងហោប៉ៅក្រៅនៃកញ្ចប់ "ខ" ។
- ធ្វើចំពោះមុខសមាជិក កបឃ/ស តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ ។

**ចំណាំ :**

ចំពោះឃុំ សង្កាត់មានការិយាល័យបោះឆ្នោតតិចប្រើកញ្ចប់ "ខ" តែមួយបានហើយ ។

**គ- ការបញ្ជូនកញ្ចប់ "ខ" មក គ.ជ.ប តាមរយៈ លធ/ខប**

- **រយៈពេលនៃការបញ្ជូនកញ្ចប់ "ខ" មក គ.ជ.ប**
  - ករណីគ្មានបណ្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតដាក់នៅ កបឃ/ស → ត្រូវបញ្ជូននៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១២ ។
  - ករណីមានបណ្តឹងតវ៉ាដាក់នៅ កបឃ/ស → ត្រូវបញ្ជូនកញ្ចប់ "ខ" នៅថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១២ ។
  - រយៈពេលនៃការបញ្ជូនកញ្ចប់ "ខ" ចេញពីឃុំ សង្កាត់ មក គ.ជ.ប មាន៩ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។




- **ការបញ្ជូនកញ្ចប់ "ខ" ទៅ លធ/ខប**
  - ស្មៀនឃុំ សង្កាត់ត្រូវបញ្ជូន និងប្រគល់កញ្ចប់ "ខ" ដោយផ្ទាល់ទៅ លធ/ខប ។
  - ក្នុងករណីចាំបាច់ លធ/ខប អាចចាត់មន្ត្រីមកប្រមូលកញ្ចប់ "ខ" ពីស្មៀនដល់ ឃុំ សង្កាត់ ។
  - ដោយឡែកកេសស័ង្កសី ត្រាការិយាល័យ តាំប៉ុង ស្លាកសម្គាល់ការិយាល័យ ទ.១០២០ ទ.១០២២ បង្កាន់ដៃដែលនៅសល់មិនទាន់ប្រើ និងទម្រង់បែបបទផ្សេងទៀត ស្មៀនត្រូវរក្សាទុកឱ្យបានល្អសម្រាប់ប្រើប្រាស់ ។

១០. ការត្រួតពិនិត្យកញ្ចប់ " ខ" និងការវេចខ្ចប់កញ្ចប់ " គ " នៅ លធ/ខប សម្រាប់បញ្ជូនទៅ គ.ជ.ប

មន្ត្រី លធ/ខប ត្រូវបើកកញ្ចប់ " ខ" នីមួយៗ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឡើងវិញ ដោយផ្អែកលើ ទ.១០១៣ ។

**ក- ការត្រួតពិនិត្យកញ្ចប់ " ខ "**

**លធ/ខប ត្រូវ**

- បើកកញ្ចប់" ខ" នីមួយៗ ។
- ដកយក ទ.១០១៣ ចំនួន ២ច្បាប់ ពីក្នុងកញ្ចប់ " ខ" មួយ(១)ច្បាប់ពីហោប៉ៅក្រៅកញ្ចប់ " ខ" និងមួយ(១)ច្បាប់ទៀតពីស្មៀន ។
- ផ្ទៀងផ្ទាត់រាល់សម្ភារៈឯកសារ ដែលមានក្នុងកញ្ចប់ " ខ" ដោយផ្អែកលើ ទ.១០១៣ ដើម្បីឱ្យដឹងថាក្នុងកញ្ចប់" ខ"មានសម្ភារៈឯកសារដូចមានចែងក្នុង ទ.១០១៣ (យកចិត្តទុកដាក់ពិនិត្យ និងរាប់ចំនួនកញ្ចប់" ក" និងស្បោងដាក់ ទ.១០២២) ។
- ចុះហត្ថលេខា និងកាលបរិច្ឆេទ បោះត្រាលើ ទ.១០១៣ ទាំង ៤ច្បាប់ ដែលត្រូវប្រើ ៖

  ទ.១០១៣ = ៤ ច្បាប់
  - ១ ច្បាប់ ច្រកចូលក្នុងស្រោមសំបុត្រ រួចដាក់ចូលក្នុងកញ្ចប់ " ខ" ពាក់ព័ន្ធវិញ ។
  - ១ ច្បាប់ ដាក់ក្នុងហោប៉ៅក្រៅកញ្ចប់ " ខ" វិញ ។
  - ១ ច្បាប់ ជូនស្មៀនវិញ ។
  - ១ ច្បាប់ ទុកឯកសារនៅ លធ/ខប ។
- ដកយក ទ.១០២១ ដែលកិបជាប់នឹងស្បោងដាក់ ទ.១០២២ ដើម្បីទុកឯកសារនៅ លធ/ខប ។
- ដកយក ទ.១០១១ ចំនួន ១ច្បាប់ ក្នុងចំណោម ២ច្បាប់ ដែលកិបជាប់ពីក្រៅកញ្ចប់ " ក " ដើម្បីមុខការ និងទុកឯកសារនៅ លធ/ខប ។
- ដកយក ទ.១០១២ ចំនួន ១ច្បាប់ ក្នុងចំណោម ២ច្បាប់ ពីក្នុងកញ្ចប់ " ខ" ដើម្បីមុខការ និងទុកឯកសារ នៅ លធ/ខប ។
- ដកយករបាយការណ៍ស្ដីពីលទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ដើម្បីធ្វើរបាយការណ៍បូកសរុបទូទាំងរាជធានី ខេត្ត ផ្ញើជូន គ.ជ.ប និងទុកជាឯកសារ ។
- រៀបចំសម្ភារៈឯកសារដាក់ចូលក្នុងកញ្ចប់ " ខ " ដូចដើមវិញ រួចចងភ្ជិតមាត់កញ្ចប់ " ខ" ត្រៀមវេចខ្ចប់និងបញ្ជូនទៅ គ.ជ.ប ។

**ខ- ការវេចខ្ចប់កញ្ចប់ " គ "**

**លធ/ខប ត្រូវដាក់ចូលក្នុងកញ្ចប់ " គ " នូវ ៖**

- រាល់កញ្ចប់" ខ" ទាំងអស់តាមលំដាប់លំដោយលេខកូដឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ។
- ស្រោមសំបុត្រដាក់ ទ.១០១៤ ចំនួន ១ ច្បាប់ ។

- ស្រោមសំបុត្រដាក់ ទ.១០១៥ ចំនួន ១ ច្បាប់( ប្រសិនបើមាន) ។
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីលទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតទូទាំងរាជធានី ខេត្ត ចំនួន ១ ច្បាប់ ។
- ទ.១០១៤ ចំនួន ១ ច្បាប់ ដាក់ក្នុងហោប៉ៅក្រៅកញ្ចប់ " គ " ។




**ចំណាំ :**

- ផ្ទៀងផ្ទាត់សម្ភារៈឯកសារក្នុងកញ្ចប់ " គ " ឡើងវិញដើម្បីឱ្យប្រាកដថាត្រឹមត្រូវហើយ មុនពេលចងភ្ជិត ។
- ប្រើប៊ិកហ្វឺតលុបមិនជ្រះ សរសេរលេខកូដរាជធានី ខេត្ត ។

**១១. ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងសម្រាប់គោលដៅនៃការកែតម្រូវ ប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ជាសាធារណៈ**

**ក- ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង**

- បិទផ្សាយមួយ (១) ច្បាប់ នៅសាលាឃុំ សង្កាត់ ។
- បិទផ្សាយមួយ(១)ច្បាប់ នៅទីតាំងណាមួយក្នុងឃុំ សង្កាត់ ។

- ធ្វើកំណត់ហេតុនៃការបិទផ្សាយចំនួនបួន (៤) ច្បាប់ ស្តីពីពេលវេលា កាលបរិច្ឆេទ ទីកន្លែងនៃការបិទផ្សាយ និងចុះហត្ថលេខា បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត ។

កំណត់ហេតុ = ៤ ច្បាប់
- ២ ច្បាប់ បិទនៅក្បែរនឹងបញ្ជីបោះឆ្នោតដំបូងទាំង២កន្លែង
- ១ ច្បាប់ ជូន គ.ជ.ប
- ១ ច្បាប់ ទុកជាឯកសារឃុំ សង្កាត់

- កបឃ/ស ស្មៀនឃុំ សង្កាត់ មេភូមិ គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវផ្សព្វផ្សាយ បំផុស និងលើកទឹកចិត្តប្រជាពលរដ្ឋអ្នកបោះឆ្នោត គ្រប់រូបឱ្យទៅមើលឈ្មោះក្នុង ៖
  - បញ្ជីបោះឆ្នោតដំបូងដែលបានបិទផ្សាយ និង
  - បញ្ជីបោះឆ្នោតដែលត្រៀមបម្រុងនឹងបិទផ្សាយ តែមិនទាន់បិទផ្សាយដោយរង់ចាំបណ្តឹងតវ៉ាត្រូវបានដោះស្រាយចប់សព្វគ្រប់សិន ។ ក្នុងករណីនេះ ប្រជាពលរដ្ឋអ្នកបោះឆ្នោតមានសិទ្ធិមកសុំមើលឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ដែលត្រៀមបម្រុងនឹងបិទផ្សាយបានដែរ ហើយ កបឃ/ស ស្មៀនឃុំ សង្កាត់ ត្រូវតែបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋអ្នកបោះឆ្នោតមកសុំមើលឈ្មោះ បានមើលឈ្មោះរបស់គាត់ ឬជួយរកឈ្មោះជូនគាត់(ប្រសិនបើគាត់សុំឱ្យជួយ) ។
- ក្នុងរយៈពេល ១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ប្រសិនបើគ្មានការតវ៉ាដោយផ្ទាល់មាត់ ឬបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ណាមួយត្រូវបានដាក់នៅ កបឃ/ស ទេ ស្មៀនឃុំ សង្កាត់ ត្រូវធ្វើរបាយការណ៍ស្តីពីករណីគ្មានការតវ៉ាដោយផ្ទាល់មាត់ ឬបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ រួចចុះហត្ថលេខា កាលបរិច្ឆេទ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងផ្ញើមក គ.ជ.ប ជាបន្ទាន់តាមរយៈ លធ/ឧប ។

**ខ- កាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង**

- បើគ្មានបណ្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះណាមួយនៅ កបឃ/ស ទេនោះ → ស្មៀនឃុំ សង្កាត់ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៅទូទាំងប្រទេសព្រមៗគ្នានៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ។
- បើមានបណ្តឹងតវ៉ាមួយ ឬច្រើនដាក់នៅ កបឃ/ស → បិទផ្សាយបញ្ជីបោះឆ្នោតដំបូងក្នុងរយៈពេលប្រាំមួយ(៦)ថ្ងៃក្រោយពីការសម្រេចរបស់ កបឃ/ស និងក្នុងករណីគ្មានបណ្តឹងបន្តនៅ គ.ជ.ប ។ គ.ជ.ប ត្រូវជូនដំណឹងជាបន្ទាន់ទៅ កបឃ/ស ។
- បើមានបណ្តឹងតវ៉ាដាក់នៅ គ.ជ.ប → បិទផ្សាយបញ្ជីបោះឆ្នោតដំបូងក្នុងរយៈពេលប្រាំមួយ (៦) ថ្ងៃក្រោយពីការសម្រេចរបស់ គ.ជ.ប និងក្នុងករណីគ្មានបណ្តឹងបន្តទៅក្រុមប្រឹក្សាធម្មនុញ្ញ។ គ.ជ.ប ត្រូវជូនដំណឹងជាបន្ទាន់ទៅ កបឃ/ស ។
- បើមានបណ្តឹងតវ៉ាដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ → បិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៅថ្ងៃបន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេច ។ គ.ជ.ប ត្រូវជូនដំណឹងជាបន្ទាន់ទៅ កបឃ/ស ។

**ចំណាំ :**

- គណបក្សនយោបាយនានាដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិសុំបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតមួយ ឬច្រើន បានចំនួន ១ច្បាប់ ដោយបង់ថ្លៃស្មើនឹងថ្លៃផលិត ។ ការផ្តល់ជូនត្រូវផ្អែកលើលទ្ធភាព និងតាមលំដាប់លំដោយនៃអ្នកស្នើសុំ។ អ្នកស្នើសុំត្រូវបង់ប្រាក់ជាមុន ១០០% នៃថ្លៃផលិត ។
- អ្នកទទួលផលិត គឺ កបឃ/ស ស្មៀន ឬ គ.ជ.ប ។
- ហាមផ្តល់ច្បាប់ដើមដល់អ្នកស្នើសុំយកទៅថតចម្លងដោយខ្លួនឯង ។

**គ- ការប្រើប្រាស់បញ្ជីបោះឆ្នោតដំបូង**

បញ្ជីបោះឆ្នោតដំបូង = ៤ ច្បាប់
- ១ ច្បាប់ បិទផ្សាយនៅសាលាឃុំ សង្កាត់
- ១ ច្បាប់ បិទផ្សាយនៅកន្លែងណាមួយសមស្របក្នុងឃុំ សង្កាត់
- ១ ច្បាប់ ជូន គ.ជ.ប
- ១ ច្បាប់ ទុកជាឯកសារឃុំ សង្កាត់

**១២. ការសុំកែតម្រូវដោយផ្ទាល់មាត់ និងការដោះស្រាយលើបញ្ជីបោះឆ្នោតដំបូង**

ការសុំកែតម្រូវដោយផ្ទាល់មាត់ ត្រូវស្ថិតក្នុងរយៈពេលដែលកំណត់ដោយច្បាប់ ។

ការសុំកែតម្រូវដោយផ្ទាល់មាត់ណាដែលពុំត្រឹមត្រូវតាមកម្មវត្ថុណាមួយដូចខាងក្រោម មិនអាចទទួលយកមកដោះស្រាយបានទេ និងត្រូវបានបដិសេធនៅនឹងកន្លែងដែលសាមីខ្លួនបានតវ៉ានោះតែម្តង ៖

**ក-ករណីនៃការសុំកែតម្រូវដោយផ្ទាល់មាត់**

- មានឈ្មោះ ឬ/និងទិន្នន័យ សរសេរខុសអក្ខរាវិរុទ្ធ (មានបង្កាន់ដៃចុះឈ្មោះ ឬបង្កាន់ដៃកែតម្រូវជាភស្តុតាង) ។
- មានឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោតដំបូងដែលត្រូវសុំលុប ។

**ខ-រយៈពេលការសុំកែតម្រូវដោយផ្ទាល់មាត់**

ត្រូវធ្វើក្នុងរយៈពេលដប់(១០)ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ដោយមិនចាំបាច់ប្រើ ទ.១២០២ ឡើយ ។

**គ-អ្នកបោះឆ្នោតមកមើលឈ្មោះ**

**អ្នកបោះឆ្នោតមកមើលឈ្មោះ** ⇒

- ឃើញឈ្មោះ ឬ/និងទិន្នន័យរបស់គាត់ តែខុសពីឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការ ឬ/និង
- ឃើញមានឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោត ។

⇒

ទៅជួបស្មៀនឃុំ សង្កាត់ ដើម្បី ៖
- សុំកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ ឬ/និង
- សុំលុបឈ្មោះស្ទួនចេញ ។

| | |
|---|---|
| ស្ទៀន ត្រូវ ⇨ | - កែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត ដោយផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ (តាមការស្នើសុំ) ដែលមានក្នុងឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការរបស់គាត់ ពិសេសអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងឱ្យអ្នកស្នើសុំផ្ដិតមេដៃលើគល់ និងចុងបង្កាន់ដៃដែលបានកែតម្រូវនោះ<br>- យក ទ.១០១៧ សុំលុបឈ្មោះស្ទួន ដើម្បីដាក់ជូន កបឃ/ស ពិនិត្យសម្រេច<br>- លុបឈ្មោះស្ទួនមួយ ឬច្រើនចេញ តាមសេចក្ដីសម្រេចរបស់ កបឃ/ស<br>- ស្រង់ឈ្មោះ ឬ/និងទិន្នន័យដែលកែតម្រូវនោះ ឬ/និងស្រង់ឈ្មោះស្ទួនដែលលុបចេញពីបញ្ជីបោះឆ្នោត ចូលក្នុង ទ.១០២០ ដើម្បីត្រៀមធ្វើរបាយការណ៍សរុបផ្ញើមកមជ្ឈមណ្ឌលកុំព្យូទ័រនៃ គ.ជ.ប នៅពេលបញ្ចប់ការសុំកែតម្រូវដោយផ្ទាល់មាត់ និងការដោះស្រាយបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ។ |

### ១៣. ការប្ដឹង ការទទួលបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ក្នុងគោលដៅកែតម្រូវបញ្ជីបោះឆ្នោតដំបូង

ការប្ដឹង និងការទទួលបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវស្ថិតក្នុងរយៈពេលដែលកំណត់ដោយច្បាប់ ។ បណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ណាដែលពុំត្រូវតាមកម្មវត្ថុណាមួយ ដូចខាងក្រោម មិនអាចទទួលយកបានទេ និងត្រូវបានបដិសេធនៅនឹងកន្លែងដែលសាមីខ្លួនដាក់ពាក្យនោះតែម្ដង ៖

| **ករណីនៃបណ្ដឹងតវ៉ា** | **ករណីនៃបណ្ដឹងជំទាស់** |
|---|---|
| - មិនឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង (មានបង្កាន់ដៃចុះឈ្មោះ ឬបង្កាន់ដៃកែតម្រូវជាភស្ដុតាង) ។<br>- មានឈ្មោះ ប៉ុន្តែឈ្មោះនោះនៅក្នុងការិយាល័យផ្សេងទៀតទៀត ។<br>- ឃើញឈ្មោះ តែត្រូវបានឆូតលុបពីបញ្ជីបោះឆ្នោតដំបូង ។ | - មានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង តែជននោះគ្មានសិទ្ធិចុះឈ្មោះ ៖<br>• មិនមានសញ្ជាតិខ្មែរ ។<br>• មិនមានអាយុស្របច្បាប់ក្នុងការបោះឆ្នោត ។<br>• មិនមានទីលំនៅក្នុងឃុំ សង្កាត់ ។<br>• ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ វិកលចរិត ស្ថិតក្រោមអាណាព្យាបាល (មានលិខិតបញ្ជាក់ពីសមត្ថកិច្ច) ។<br>- មានឈ្មោះលើសពីមួយ(១) ក្នុងបញ្ជីបោះឆ្នោត ។ |
| **ក- ការប្ដឹង ការទទួលបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់នៅ កបឃ/ស និងការប្រជុំសម្រេចជាសាធារណៈ** | |
| **ក.១/ការប្ដឹងតវ៉ា**<br>- ការប្ដឹងតវ៉ាត្រូវធ្វើក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។<br>**ក.២/ការទទួលបណ្ដឹង**<br>- ទ. ១២០២ = ៣ច្បាប់ ចុះកាលបរិច្ឆេទ ពេលវេលាទទួល កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងប្រជុំសម្រេច<br>ទ.១២០២ = ៣ច្បាប់ {<br>- ១ ច្បាប់ ជូនអ្នកប្ដឹងតវ៉ា ឬតំណាង<br>- ១ ច្បាប់ បិទផ្សាយនៅឃុំ សង្កាត់<br>- ១ ច្បាប់ ទុកប្រើប្រាស់ក្នុងការប្រជុំសម្រេច | **ការប្ដឹងជំទាស់**<br>- ការប្ដឹងជំទាស់ត្រូវធ្វើក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។<br>**ការទទួលបណ្ដឹង**<br>- ទ. ១២០២ = ៤ច្បាប់ ចុះកាលបរិច្ឆេទ ពេលវេលាទទួល កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងប្រជុំសម្រេច<br>ទ.១២០២=៤ច្បាប់ {<br>- ១ ច្បាប់ ជូនអ្នកប្ដឹងជំទាស់ឬតំណាង<br>- ១ ច្បាប់ ជូនអ្នកត្រូវគេប្ដឹង<br>- ១ ច្បាប់ បិទផ្សាយនៅឃុំ សង្កាត់<br>- ១ ច្បាប់ ទុកប្រើពេលប្រជុំសម្រេច |

| | |
|---|---|
| - ស្មៀនត្រូវតែមានវត្តមាន ដើម្បីផ្តល់ព័ត៌មានជូន កបយ/ស<br>- អ្នកប្តឹងបង្ហាញឯកសារភស្តុតាង ឬសាក្សី ។ | - ជូនដំណឹងទៅអ្នកដែលត្រូវគេប្តឹង ។<br>- ស្មៀនត្រូវមានវត្តមាន ដើម្បីផ្តល់ព័ត៌មាន ។<br>- អ្នកប្តឹងជំទាស់ត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សី ។<br>- អ្នកត្រូវគេប្តឹងមានសិទ្ធិបដិសេធដោយបង្ហាញឯកសារ ។ |
| **ក.៣/ការប្រជុំសម្រេចជាសាធារណៈ(រយៈពេល៣ថ្ងៃ )** | **ការប្រជុំសម្រេចជាសាធារណៈ (រយៈពេល ៣ថ្ងៃ )** |
| **ករណីបដិសេធ** | **ករណីបដិសេធ** |
| - ស្រង់សេចក្តីសម្រេចបដិសេធដាក់ក្នុង ទ.១២០៣ = ៣ ច្បាប់ បញ្ជាក់មូលហេតុ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់ ។<br>ទ. ១២០៣ = ៣ ច្បាប់ {<br>- ១ ច្បាប់ ជូនអ្នកប្តឹងតវ៉ាឬតំណាង<br>- ១ ច្បាប់ ជូន គ.ជ.ប<br>- ១ ច្បាប់ ទុកជាឯកសារ<br>- ជូន ទ. ១២០២ = ៣ច្បាប់ ដល់អ្នកប្តឹង (បើសុំ ) → ជម្រាបគាត់ឱ្យបំពេញចំនួន ៣ច្បាប់ → រួចយកទៅដាក់នៅ គ.ជ.ប យ៉ាងយូរ ៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។ | - ស្រង់សេចក្តីសម្រេចបដិសេធដាក់ក្នុង ទ.១២០៣= ៤ច្បាប់ បញ្ជាក់មូលហេតុ ចុះហត្ថលេខា កាលបរិច្ឆេទ និង បោះត្រាឃុំ សង្កាត់ ។<br>ទ.១២០៣ = ៤ ច្បាប់ {<br>- ១ ច្បាប់ ជូនអ្នកប្តឹងជំទាស់<br>- ១ ច្បាប់ ជូនអ្នកត្រូវគេប្តឹង<br>- ១ ច្បាប់ ជូន គ.ជ.ប<br>- ១ ច្បាប់ ទុកជាឯកសារ<br>- ជូន ទ.១២០២ = ៤ច្បាប់ដល់អ្នកប្តឹង (បើសុំ) → ជម្រាបគាត់ឱ្យបំពេញ រួចយកមកដាក់នៅ គ.ជ.ប រយៈពេលយ៉ាងយូរ៥ ថ្ងៃ បន្ទាប់ពីថ្ងៃទទួល ទ.១២០៣ ។ |
| **ករណីយល់ព្រម** | **ករណីយល់ព្រម** |
| - ស្រង់សេចក្តីសម្រេចយល់ព្រមដាក់ក្នុង ទ.១២០៣ → ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់ ។<br>ទ.១២០៣ = ៣ ច្បាប់ {<br>- ១ ច្បាប់ ជូនអ្នកប្តឹងតវ៉ា ឬតំណាង<br>- ១ ច្បាប់ ជូន គ.ជ.ប<br>- ១ ច្បាប់ ទុកជាឯកសារ<br>- ស្មៀនអនុវត្តតាមសេចក្តីសម្រេច → កត់ត្រាទុកក្នុង ទ . ១០២០ ដើម្បីត្រៀមធ្វើរបាយការណ៍សរុបបញ្ជូនមកមជ្ឈមណ្ឌលកុំព្យូទ័រនៃ គ.ជ.ប នៅពេលបញ្ចប់ការដោះស្រាយបណ្តឹង ។ | - ស្រង់សេចក្តីសម្រេចយល់ព្រមដាក់ក្នុង ទ.១២០៣ → ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់ ។<br>ទ.១២០៣ = ៤ ច្បាប់ {<br>- ១ ច្បាប់ ជូនអ្នកប្តឹងជំទាស់ ឬតំណាង<br>- ១ ច្បាប់ ជូនអ្នកត្រូវគេប្តឹង<br>- ១ ច្បាប់ ជូន គ.ជ.ប<br>- ១ ច្បាប់ ទុកជាឯកសារ<br>- ជូន ទ.១២០២ = ៤ច្បាប់ដល់អ្នកត្រូវគេប្តឹង (បើសុំ) → ជម្រាបគាត់ឱ្យបំពេញ រួចយកមកដាក់នៅ គ.ជ.ប រយៈពេលយ៉ាងយូរ ៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួល ទ.១២០៣ ។<br>- ស្មៀនគូសបន្ទាត់លុបឈ្មោះអ្នកដែលត្រូវគេប្តឹង រួចចារថា " ប្តឹងជំទាស់ "។ ស្រង់កត់ត្រាទុកក្នុង ទ.១០២០ ត្រៀមធ្វើរបាយការណ៍សរុប រួចបញ្ជូនមកមជ្ឈមណ្ឌលកុំព្យូទ័រនៃ គ.ជ.ប នៅពេលបញ្ចប់ការដោះស្រាយបណ្តឹង ។ |
| **ខ- ការប្តឹង ការទទួលបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នៅ គ.ជ.ប និងការបើកសវនាការជាសាធារណៈ** | |
| **ខ.១/ការប្តឹងតវ៉ា** | **ការប្តឹងជំទាស់** |
| - ការប្តឹងតវ៉ាត្រូវធ្វើក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរបន្ទាប់ពីបាន ទទួលសម្រង់សេចក្តីសម្រេចបដិសេធ (ទ.១២០៣) របស់ កបយ/ស ។ | - ការប្តឹងជំទាស់ត្រូវធ្វើក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរបន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចបដិសេធ (ទ.១២០៣) របស់ កបយ/ស ។ |
| **ខ.២/ការទទួលបណ្តឹង** | **ការទទួលបណ្តឹង** |
| - ការទទួលបណ្តឹងត្រូវធ្វើរយៈពេល ៥ថ្ងៃយ៉ាងយូរបន្ទាប់ | - ការទទួលបណ្តឹងត្រូវធ្វើរយៈពេល៥ថ្ងៃយ៉ាងយូរបន្ទាប់ |

<table>
<tr>
<td>
ពិ កបឃ/ស ប្រគល់សម្រង់សេចក្ដីសម្រេច (ទ.១២០៣) ដល់អ្នកប្ដឹង ឬតំណាង ។<br><br>
ទ.១២០២=៣ ច្បាប់<br>
- ១ ច្បាប់ ជូនអ្នកប្ដឹង<br>
- ១ ច្បាប់ បិទផ្សាយនៅ គ.ជ.ប<br>
-១ ច្បាប់ ទុកប្រើពេលសវនាការ<br><br>
ខ.៣/ការសម្រេចរបស់ គ.ជ.ប រយៈពេល ៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០២<br>
ករណីបដិសេធ<br>
- ស្រង់សេចក្ដីសម្រេចបដិសេធដាក់ក្នុងទ.១២០៣= ៣ច្បាប់→ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ។<br><br>
ទ.១២០៣=៣ ច្បាប់<br>
- ១ច្បាប់ជូនអ្នកប្ដឹងតវ៉ា ឬតំណាង<br>
- ១ ច្បាប់ ជូនក្រុមប្រឹក្សាធម្មនុញ្ញ<br>
-១ ច្បាប់ ទុកជាឯកសារ<br><br>
- អ្នកប្ដឹងតវ៉ា → ប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ។<br>
ករណីយល់ព្រម<br>
- ស្រង់សេចក្ដីសម្រេចយល់ព្រមដាក់ក្នុងទ.១២០៣ ចំនួន= ៣ ច្បាប់→ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ។<br><br>
ទ.១២០៣ = ៣ ច្បាប់<br>
- ១ ច្បាប់ ជូនអ្នកប្ដឹងតវ៉ា<br>
- ១ ច្បាប់ ជូន កបឃ/ស → ស្មៀនអនុវត្ត<br>
- ១ ច្បាប់ ទុកជាឯកសារ<br><br>
- ស្មៀនចុះឈ្មោះបន្ថែម ឬរក្សាទុកឈ្មោះ និងកត់ត្រាទុកក្នុង ទ.១០២០ ដើម្បីត្រៀមធ្វើរបាយការណ៍សរុប ផ្ញើមកមជ្ឈមណ្ឌលកុំព្យូទ័រនៃ គ.ជ.ប នៅពេលបញ្ចប់ការដោះស្រាយបណ្ដឹង ។
</td>
<td>
ពិ កបឃ/ស ប្រគល់សម្រង់សេចក្ដីសម្រេច (ទ.១២០៣) ដល់អ្នកប្ដឹង ឬតំណាង ។<br><br>
ទ.១២០២ = ៤ ច្បាប់<br>
- ១ ច្បាប់ ជូនអ្នកប្ដឹង<br>
- ១ ច្បាប់ ជូនអ្នកត្រូវគេប្ដឹង<br>
- ១ ច្បាប់ បិទផ្សាយនៅ គ.ជ.ប<br>
- ១ ច្បាប់ ទុកប្រើពេលសវនាការ<br><br>
ការសម្រេចរបស់ គ.ជ.ប រយៈពេល ៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០២<br>
ករណីបដិសេធ<br>
- ស្រង់សេចក្ដីសម្រេចបដិសេធដាក់ក្នុងទ.១២០៣ = ៤ ច្បាប់ → ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ។<br><br>
ទ.១២០៣= ៤ ច្បាប់<br>
- ១ ច្បាប់ ជូនអ្នកប្ដឹងជំទាស់<br>
- ១ ច្បាប់ ជូនអ្នកត្រូវគេប្ដឹង<br>
- ១ ច្បាប់ ជូនក្រុមប្រឹក្សាធម្មនុញ្ញ<br>
- ១ ច្បាប់ ទុកជាឯកសារ<br><br>
- អ្នកប្ដឹងជំទាស់ → ប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ។<br>
ករណីយល់ព្រម<br>
- ស្រង់សេចក្ដីសម្រេចយល់ព្រមដាក់ក្នុងទ.១២០៣ ចំនួន=៥ ច្បាប់ → ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ។<br><br>
ទ.១២០៣ = ៥ ច្បាប់<br>
- ១ ច្បាប់ ជូនអ្នកប្ដឹងជំទាស់<br>
- ១ ច្បាប់ ជូនអ្នកត្រូវគេប្ដឹង<br>
- ១ ច្បាប់ ជូនក្រុមប្រឹក្សាធម្មនុញ្ញ<br>
- ១ ច្បាប់ ជូន កបឃ/ស → ស្មៀនអនុវត្ត<br>
- ១ ច្បាប់ ទុកជាឯកសារ<br><br>
- អ្នកត្រូវគេប្ដឹង → ប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ។<br>
- ស្មៀនគូសបន្ទាត់លុបឈ្មោះ → ចារថា " ប្ដឹងជំទាស់ " ។ ស្រង់កត់ត្រាទុកក្នុង ទ.១០២០ → ដើម្បីត្រៀមធ្វើរបាយការណ៍សរុប → ជូនមជ្ឈមណ្ឌលកុំព្យូទ័រនៃ គ.ជ.ប នៅពេលបញ្ចប់ការដោះស្រាយបណ្ដឹង ។
</td>
</tr>
</table>

**គ- ការប្ដឹង ការទទួលបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់នៅក្រុមប្រឹក្សាធម្មនុញ្ញ និងការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ**

- ការប្ដឹងមានរយៈពេល ៥ ថ្ងៃ បន្ទាប់ពីថ្ងៃទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គ.ជ.ប ។
- ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (រយៈពេល ១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង) ។

- **ករណីសម្រេចបដិសេធបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់**
  - ចេញសេចក្ដីសម្រេចបដិសេធបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ។

សេចក្ដីសម្រេចបដិសេធ= ២ច្បាប់
- ១ ច្បាប់ ជូនអ្នកប្ដឹងតវ៉ា ឬអ្នកប្ដឹងជំទាស់ ឬអ្នកត្រូវគេប្ដឹងជំទាស់ ។
- ១ ច្បាប់ ជូន គ.ជ.ប ។

- **ករណីសម្រេចយល់ព្រមតាមបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់**
  - ចេញសេចក្ដីសម្រេចយល់ព្រមតាមបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ។

សេចក្ដីសម្រេចយល់ព្រម= ២ច្បាប់
- ១ ច្បាប់ ជូនអ្នកប្ដឹងតវ៉ា ឬអ្នកប្ដឹងជំទាស់ ឬអ្នកត្រូវគេប្ដឹងជំទាស់ ។
- ១ ច្បាប់ ជូន គ.ជ.ប ។

- គ.ជ.ប ត្រូវជូនដំណឹងទៅ កបឃ/ស ឱ្យបានឆាប់រហ័សតាមរយៈទូរសារ ឬវិទ្យុទាក់ទង និងផ្ញើច្បាប់ដើមនូវរាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ទាំងសេចក្ដីសម្រេចយល់ព្រម ឬ/និងទាំងសេចក្ដីសម្រេចបដិសេធបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់) តាមរយៈ លធ/ខប ។

**ចំណាំ :**

- រាល់សេចក្ដីសម្រេចបដិសេធទាំងបណ្ដឹងតវ៉ា ទាំងបណ្ដឹងជំទាស់ → ត្រូវរក្សាទុកបញ្ជីបោះឆ្នោតនៅដដែល ។
- រាល់សេចក្ដីសម្រេចយល់ព្រមតាមបណ្ដឹងតវ៉ា → ចុះឈ្មោះ ឬរក្សាទុកឈ្មោះបន្ថែមជាបន្ទាន់ក្នុងបញ្ជីបោះឆ្នោត ។
- រាល់សេចក្ដីសម្រេចយល់ព្រមតាមបណ្ដឹងជំទាស់→ ត្រូវគូសបន្ទាត់លុបឈ្មោះ និងចារថា " ប្ដឹងជំទាស់ " ។
- កត់ត្រាទុកក្នុង ទ. ១០២០ នូវ ៖
  - ឈ្មោះ ឬ/និងទិន្នន័យដែលបានកែតម្រូវ ។
  - ឈ្មោះដែលបាត់ ហើយត្រូវបានចុះបន្ថែមនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យពាក់ព័ន្ធ ។
  - ឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានលុបចេញពីបញ្ជីបោះឆ្នោតដំបូង ។

**ឃ- ចន្លោះពេលចាប់ពីការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង រហូតដល់ចប់ការប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ ស្មៀនឃុំសង្កាត់ត្រូវធ្វើសុក្រឹតភាពបញ្ជី ៖**

- ស្រង់ឈ្មោះអ្នកបោះឆ្នោតដែលទទួលមរណភាព ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាល ឬស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ។
- បំពេញក្នុងបញ្ជីដោយឡែក និងមានឯកសារភស្តុតាងផង ដាក់ជូន កបឃ/ស បញ្ជាក់ឯកភាព ។
- លុបឈ្មោះ ហើយចារថា ស្លាប់ ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាល ឬជាប់ពន្ធនាគារ ។

**ង- ពេលបញ្ចប់ដំណើរការប្ដឹង និងដោះស្រាយបណ្ដឹងរួចគ្រប់ថ្នាក់ → ធ្វើរបាយការណ៍សរុប ដោយបំពេញ ទ.១០២០ ដែលមានតារាងភ្ជាប់ជាមួយ និងឯកសារបញ្ជាក់ (ប្រសិនបើមាន) ផ្ញើជូន គ.ជ.ប (មជ្ឈមណ្ឌលកុំព្យូទ័រ) តាមរយៈ លធ/ខប ។**

# គំនូសបំព្រួញរយៈពេលនៃការដាក់/ទទួល និងដោះស្រាយពាក្យបណ្តឹងក្នុងដំណាក់កាលនៃការមិនផ្សាយបញ្ជីបោះឆ្នោតដំបូង

## ក- ករណីពាក្យបណ្តឹងតវ៉ា



## ខ- ករណីពាក្យបណ្តឹងជំទាស់



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២

## ប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១២

## ( វិសោធនកម្ម )

| ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការចុះឈ្មោះអ្នកសង្កេតការណ៍ | ថ្ងៃទី ១៦ ខែ សីហា - ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ |
| ការចុះឈ្មោះតំណាងគណបក្សនយោបាយ | ថ្ងៃទី ២៣ ខែ សីហា - ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១២ |
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ (បញ្ជីបោះឆ្នោតឆ្នាំ២០១១) នៅសាលាឃុំ សង្កាត់ | ថ្ងៃទី ៣០-៣១ ខែ សីហា ឆ្នាំ ២០១២ |
| ការចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ | ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១២ |
| ការបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ | ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១២ |
| ការប្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការប្តឹងតវ៉ានឹងការបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការប្តឹងតវ៉ានឹងការបដិសេធរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការបិទផ្សាយព្រមគ្នាបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ដែលគ្មានបណ្តឹងតវ៉ា | ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ |
| ការប្តឹងតវ៉ា ឬជំទាស់លើបញ្ជីបោះឆ្នោតដំបូងទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការប្តឹងតវ៉ា ឬជំទាស់នឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការប្តឹងតវ៉ា ឬជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ដែលមានបណ្តឹងតវ៉ា | ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ដំណើរការដាក់ និងដោះស្រាយបណ្តឹងលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ មានបណ្តឹង | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ( ថ្ងៃចុងក្រោយ ) |
| ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតឆ្នាំ២០១២ ដោយ គ.ជ.ប | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ |

# តារាងសង្ខេបទម្រង់បែបបទដែលត្រូវប្រើប្រាស់តាមលំដាប់ថ្នាក់

| ស្មៀនឃុំ សង្កាត់ | | ក្រុមប្រឹក្សាឃុំ សង្កាត់ | | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | |
|---|---|---|---|---|---|
| លេខទម្រង់ | ខ្លឹមសារ | លេខទម្រង់ | ខ្លឹមសារ | លេខទម្រង់ | ខ្លឹមសារ |
| ១.១០០៩ | សេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត | ១.១០០១ | កិច្ចសន្យាបម្រើការងារជាមន្ត្រីចុះឈ្មោះបោះឆ្នោត | ១.១០១៤ | លិខិតបញ្ជាក់ការវេចខ្ចប់កញ្ចប់ "ខ" និងការបញ្ជូនកញ្ចប់ "គ" ដោយ លច/ខប |
| ១.១០១១ | របាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត | ១.១០០៦ | បញ្ជីវត្តមាន និងប្រាក់កម្រៃមន្ត្រីចុះឈ្មោះបោះឆ្នោត | ១.១០១៥ | លិខិតបញ្ជាក់សុពលភាពនៃការប្រើប្រាស់សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោតបម្រុងដែលផ្គត់ផ្គង់បន្ថែម |
| ១.១០១២ | របាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ | ១.១០០៧ | ពាក្យសុំចុះឈ្មោះភ្នាក់ងារនៃគណបក្សនយោបាយ និងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ គឃ/គសប | ១.១១០៧ | លិខិតបញ្ជូន និងប្រគល់-ទទួលសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត |
| ១.១០១៣ | លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនកញ្ចប់ "ខ" ដោយស្មៀនឃុំ សង្កាត់ | ១.១០១៩ | លិខិតបញ្ជាក់ទីលំនៅ | | |
| ១.១០១៦ | ទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ករណីស្លាប់ ឬបាត់បង់សិទ្ធិ ឬផ្លាស់ចេញ ឬគ្មានទីលំនៅអចិន្ត្រៃយ៍ ឬបណ្ដោះអាសន្នក្នុងឃុំ សង្កាត់) | ១.១១០៧ | លិខិតបញ្ជូន និងប្រគល់-ទទួលសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត | | |
| ១.១០១៧ | ទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ករណីប្ដូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់តែមួយ ឬផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់ ឬឈ្មោះស្ទួន) | ១.១២០២ | ពាក្យបណ្ដឹង | | |
| ១.១០២០ | របាយការណ៍កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ | ១.១២០៣ | សម្រង់សេចក្ដីសម្រេច | | |
| ១.១០២១ | របាយការណ៍ស្ដីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត | | លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត | | |
| ១.១០២២ | ទម្រង់បែបបទចុះឈ្មោះបោះឆ្នោត/បង្កាន់ដៃ | | របាយការណ៍ស្ដីពីលទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត | | |
| ១.១០២៥ | បញ្ជីរាយនាមអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត | ១.១០២៥ | បញ្ជីរាយនាមអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត | | |
| ១.១០២៦ | បញ្ជីឈ្មោះស្ទួនក្នុងឃុំ សង្កាត់ ស្រង់ដោយ គ.ជ.ប | ១.១០២៦ | បញ្ជីឈ្មោះស្ទួនក្នុងឃុំ សង្កាត់ ស្រង់ដោយ គ.ជ.ប | | |
| ១.១០២៣ | បញ្ជីបោះឆ្នោតបន្ថែម/បញ្ជីបោះឆ្នោតដែលបានចុះឈ្មោះថ្មី | | | | |
| ១.១១០៧ | លិខិតបញ្ជូន និងប្រគល់-ទទួលសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត | | | | |
| ១.១២០២ | ពាក្យបណ្ដឹង | | | | |
| ១.១០២៨ | បង្កាន់ដៃទទួលកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត | | | | |

បោះពុម្ពដោយ គ.ជ.ប

ឆ្នាំ ២០១២